លេខ ៤

# មិត្តសាលាបាលី

ផ្សាយរឿង

សាសនា អក្សរសាស្ត្រ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រ

១




ព.ស. ២៤៩៨

គ.ស. ១៩៥៥

ខែ សីហា

ចេតិយអនុស្សាវរីយ៍សារីរិកធាតុ

ទីចាត់ការ វត្តលង្កា សង្កាត់លេខ ៦ ក្រុងភ្នំពេញ

បណ្ណាធិការ ឃួត-ហៀម

# មាតិការឿង


| | | | |
|---|---|---|---|
| បណ្ណាធិការ | វិចារណកថា | ទំព័រទី | ១ |
| ព្រះគ្រូបុរត្ថិមវាសី អ៊ូ-ចេវ | បវរិត្តកុប្បញ្ហា | ” | ៣ |
| សៅ-ចេស | សម្មាសាមគ្គីនិងធម្មសាមគ្គី | ” | ១០ |
| មហា មាស-ឆាន់ | ការសិក្សាក្នុងប្រទេសជប៉ុន | ” | ១១ |
| ហ៊ុយ-ប៉ុគា | ហេតុដូចម្ដេចបានជានាងខ្ញុំ | ” | ១៧ |
| មហា ហ៊ុយ-អ៊ូច | និទានខ្លីៗ | ” | ២០ |
| | ប្រវត្តិក្មេងកំព្រា | ” | ២២ |
| ប្រសិតបញ្ចន់ប័ត្ត | ការធ្វើស្ករ | ” | ២៦ |
| មហា ទ៉ាន់-ខាត់ | បញ្ចគ្រឹះ | ” | ២៨ |
| ហ៊ុយ-ប៉ុគា | រឿងទុក្កតាធ្វើពីធម្មជាតិ | ” | ៣០ |
| ស្ទូន-សុរិដ្ឋ | ១- ជីវិតអភ័ព្វ | ” | ៣២ |


## ដំឡៃជាវ

| ក្នុងប្រទេស | | | ក្រៅប្រទេស | | |
|---|---|---|---|---|---|
| ៦ខែ | ១ឆ្នាំ | ១ក្បាល | ៦ខែ | ១ឆ្នាំ | ១ក្បាល |
| ៥០\|០០ | ១០០\|០០ | ១០\|០០ | ៦០\|០០ | ១២០\|០០ | ១៣\|០០ |

អ្នកណាចង់ចូលឲ្យជាវ


សូមផ្ញើបំពោះទៅលោក ម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ

**ADRESSE**: Monsieur **MAO-MEY** Ministère de L'Intérieur P.Penh

R. le 19-10-55




# ការស្ថាបនាអនុស្សាវរីយ៍

## ព្រះសារីរិកធាតុ

ដំណើរដែលព្រះបរមសារីរិកធាតុនៃព្រះសម្មាសម្ពុទ្ធជាបរមគ្រូ មួយអន្លើដោយព្រះអរហន្តធាតុនៃព្រះសារីបុត្រនិងព្រះមោគ្គល្លាន ជាអគ្គសាវ័កទាំងគូ បានអណ្ដែតត្រសែតពីមជ្ឈិមប្រទេសមកកាន់កម្ពុជប្រទេសយើងនៅពុទ្ធសតវត្សរ៍ទី២៥ ត្រង់ព.ស.២៤៩៥ នោះ ជានិមិត្តរូបមួយខាងក័ព្វសនាដែលជាហេតុបណ្ដាលឲ្យកម្ពុជរដ្ឋបានជួបប្រទះនូវអធិបតេយ្យភាព និងសុខភាពក្នុងផ្ទៃប្រទេសយ៉ាងគ្រប់គ្រាន់ ។

យើងមិនមែនចេះតែលើកដម្កើងព្រះពុទ្ធសាសនាហួសហេតុទេ, តែរឿងនេះ បើពិភពលោកស្ដាប់ស្ទង់មើលដោយវិចារណញ្ញាណដ៏ជ្រាលជ្រៅហ្មត់ចត់គង់ឃើញបានថា តាំងតែពិភពលោកស្វែងរកសន្តិភាពដោយយកសម្ភារៈជាអាវុធមក ពុំដែលឃើញបានជួបប្រទះនឹងសន្តិភាពបន្តិចបន្តួចសោះឡើយ, ឃើញចេះតែកើតអសន្តិភាពថែមឡើងទៀត; ទើបតែឥឡូវនេះដែលពិភពលោកបែរគំនិតមកស្វែងរកសន្តិភាពដោយផ្លូវមួយទៀត គឺស្វែងរកដោយយកគោលធម៌ដែលកើតដោយបំហាយព្រះបរមសារីរិកធាតុជាអាវុធខ្លះ ក៏សន្តិភាពអាចបញ្ចេញរស្មីឲ្យពិភពលោកបានដឹងឮឃើញព្រិលៗខ្លះហើយ ។

យើងហ៊ានពោលបញ្ជាក់ដោយអាងហេតុយ៉ាងខ្លីបំផុតថា ចាប់តាំងពីពេលដែលពិភពលោកបានដឹងថាគេរកឃើញពិតនូវព្រះបរមសារីរិកធាតុដែលកប់បាត់ជាច្រើនពាន់ឆ្នាំ នៅជម្ពូទ្វីបនោះមក, ក៏បណ្ដាលឲ្យជម្ពូទ្វីបនិងពិភពលោកឈមមុខរកគ្នា មើលមុខគ្នាត្រង់រួមគ្នាជាមិត្ត យកចិត្តទុកដាក់ចំពោះសន្តិភាពពិតៗ តែ

តែចំរើនឡើង ដោយបំបែកទ្រនិងសទ្ធិភាពទៅតាមផ្ទៃធំដែលកើតឡើងដោយចំហាយព្រះបរមសារីរិកធាតុខ្លះ ៗ នេះហើយជាផ្ទាំងកញ្ចក់មួយដែលចក្ខុរបស់លោកជនអាចធ្លុះមើលឃើញស្រមោលរូបសទ្ធិភាពយ៉ាងជាក់ស្តែង មិនបាច់ចក្ខុរបស់ពុទ្ធជនឡើយ ៗ

ចំពោះកម្ពុជប្រទេស, យើងសូមបញ្ជាក់ជាថ្មីទៀតថា: កាលព្រះសម្មាសម្ពុទ្ធជាបរមគ្រូទ្រង់ព្រះធរមាននៅឡើយ ទោះព្រះអង្គក្តី ព្រះអគ្គសាវកក្តី ពុំដែលយាង-និមន្តមកទេ, ប្រជាជនខ្មែរក៏ពុំដែលបានឃើញព្រះភក្ត្រ និងពុំដែលបានស្តាប់ព្រះធម៌ផ្ទាល់ព្រះឱស្ឋដែរ, បានតែព្រះពុទ្ធសាសនាផ្សាយមកប្រោសសត្វជំនួសព្រះអង្គក្នុងវេលាដែលទ្រង់បរិនិព្វានទៅហើយ ៗ ព្រះពុទ្ធសាសនាក៏បានចាក់ឫសចាក់គល់នៅក្នុងប្រទេសនេះជាច្រើនសតវត្សរ៍ ដរាបដល់រលាយជាសាច់ជាឈាមខ្មែរទូទាំងប្រទេស ៗ

តាំងពីព្រះពុទ្ធសាសនាផ្សាយមកដល់ មានដំណាលថា ព្រះបរមសារីរិកធាតុបាននិមន្តមកកាន់ប្រទេសខ្មែរខ្លះដែរ, តែព្រះធាតុព្រះអគ្គសាវកមិនដែលនិមន្តមកជាមួយដូចកាល ព.ស. ២៤៩៥ គ.ស. ១៩៥២ ដែលព្រះបរមសារីរិកធាតុ ព្រមទាំងព្រះធាតុព្រះអគ្គសាវកទាំងគូបានយាងបាននិមន្តតាមអាកាសយានអំពីប្រទេសឥណ្ឌាមកប្រថាប់នៅព្រះរាជធានីក្រុងភ្នំពេញ ក្នុងព្រះវិហារព្រះកែវមរកត ទុកដូចជាទ្រង់យាង-និមន្តមកបង្ហាញព្រះភក្ត្រឲ្យប្រជាជនកម្ពុជរដ្ឋបានទស្សនាគ្រប់គ្នាអស់ថិរវេលា ៨ ថ្ងៃ គឺតាំងពីថ្ងៃទី ៥ ដល់ថ្ងៃទី ១១ ខែតុលា ទើបយាង-និមន្តត្រឡប់ទៅវិញ ៗ

វេលានោះ កក្រើកអឺកធឹកយ៉ាងអស្ចារ្យ ប្រជាជនខ្មែរទាំងប្រទេសមានសទ្ធាជ្រះថ្លាណាស់ សំគាល់ថាដូចព្រះពុទ្ធជាម្ចាស់ នឹងព្រះអគ្គសាវកទាំងគូគង់ព្រះជន្មនៅឡើយ បានយាងបាននិមន្តមកប្រោសខ្លួនរៀងខ្លួន បាននាំគ្នាទាំងសែនលាននាក់មកនមស្ការបូជាព្រះអង្គ សូម្បីតែជនបរទេសដែលនៅអាស្រ័យក្នុងរដ្ឋនេះ ក៏ទប់ខ្លួនក្នុងគ្រឹះស្ថានរបស់ខ្លួនពុំនឹង សឹងតែនាំគ្នាមកទស្សនា នមស្ការ បូជា ទោះបីមានរវល់យ៉ាងណាក៏ស៊ូលះបង់ការងារ ធ្វើដំណើរមកកាន់ព្រះរាជធានី ក្រុងភ្នំពេញ រាល់រូប, ភ្នាក់ងាររាជការគ្រប់ឋានៈ តាំងពីរដ្ឋមន្ត្រីជាអាទិ៍ក៏បង្អង់ការងាររបស់ប្រទេសមួយគ្រាសិន ទាំងព្រះរាជាជាអគ្គប្រមុខរដ្ឋព្រមទាំងព្រះរាជវង្សានុវង្ស ក៏ទ្រង់ផ្អាកព្រះរាជករណីយ៍ មកទ្រង់ធ្វើគារវកិច្ចដោយពេញព្រះរាជហឫទ័យ ព្រមទាំងទ្រង់ចំណាយព្រះរាជទ្រព្យផ្ទាល់ព្រះអង្គជាច្រើនធ្វើសក្ការបូជាជាទុឡារិក ៗ

ក្នុងពេលដង្ហែពីចំណតអាកាសយានពោធិ៍ចិនតុងមកក្រុងភ្នំពេញ ជាពិធីធំមហោឡារដែលមានមហាជនរាប់លាននាក់មកហែដោយសោមនស្សនោះ, បើប្រសិនជាពិធីដទៃក្រៅពីការដង្ហែព្រះបរមសារីរិកធាតុវិញ ប្រហែលជាមានជួបប្រទះនឹងគ្រោះថ្នាក់ខ្លះ បើមិនច្រើនក៏តិចពុំខាន, ប៉ុន្តែហេតុតែដោយអំណាចព្រះពុទ្ធគុណ

មកសណ្ឋិតលើចិត្តប្រជាជនទាំងលាននាក់ ក៏ទៅជាបានសុខសប្បាយយ៉ាងក្រៃលែង ។ ពិធីបុណ្យនៅបរិវេណព្រះវិហារព្រះកែវមរកតអស់ថិរវេលា ៧ យប់ ៧ ថ្ងៃនោះសោតក៏អស្ចារ្យណាស់ សុខសប្បាយណាស់ ហួសពណ៌នា ដូចអស់លោកជ្រាបស្រាប់ហើយ មិនបាច់ពណ៌នាទេ ។

ក្នុងពិធីបុណ្យនោះ មានពីរថ្ងៃ ជាថ្ងៃអស្ចារ្យបំផុត គឺថ្ងៃទី ៥ តុលា ដែលហែមកពីចំណតអាកាសយានពោធិចិនតុង និងថ្ងៃទី ៦ តុលា ដែលហែព័ទ្ធក្រុងភ្នំពេញ ដោយមានប្រជាជនចំនួនជិតសែនលាននាក់មកដង្ហែយ៉ាងអ៊ឹកធឹកហួសពណ៌នា ។ ចំពោះថ្ងៃហែព័ទ្ធក្រុងភ្នំពេញនោះ ក្បួនហែបានចេញអំពីព្រះវិហារព្រះកែវមរកត ព័ទ្ធព្រះរាជធានីទៅប្រជុំនៅមុខស្ថានីយ៍អយស្ម័យយានដែលជាទីមហាសន្និបាតនៃប្រតិភូព្រះពុទ្ធសាសនាអំពីនានាប្រទេសមកថ្លែងសេចក្តីទទួលអំណរនឹងធ្វើការកិច្ចរៀងខ្លួន ។ ទីនេះហើយដែលឥឡូវនេះ គេបានចាត់ការសាងព្រះចេតិយមួយទុកជាអនុស្សាវរីយ៍ ។ ព្រះចេតិយនេះគួរឲ្យយើងចាប់ចិត្តយ៉ាងក្រៃលែង ដោយចំណុចនៃពុទ្ធជនទូទៅទាំងកម្ពុជរដ្ឋ, តែតាមដំណឹងខ្លះដែលយើងបានឮពីក្រុមពុទ្ធជននៅតំបន់នានា គេថា: ព្រះចេតិយនេះមិនទាន់សមសួននឹងកិត្តិគុណរបស់ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៅឡើយ ព្រោះមានកំពស់មិនស្មើនឹងស្ថានីយ៍អយស្ម័យយាននេះមួយ ហើយមួយទៀតមិនស្មើនឹងវិហារកាតូលិក ដែលគេមកប្រតិស្ឋាននៅក្នុងប្រទេសយើង ដោយមានអ្នកជឿកាន់មិនបានទាំង ១/២ ភាគ ១០ នៃសាសនាយើងផង ម្តេចក៏គេសាងវិហារគេបានធំខ្ពស់ជាងព្រះចេតិយអនុស្សាវរីយ៍ព្រះសារីរិកធាតុនៃព្រះជាបរមគ្រូយើងពីរបីដងបាន ?

ដែលពោលមកនេះ គ្រាន់តែជូនយោបល់ខ្លះប៉ុណ្ណោះ, មិនមែនសុំកែការដែលគណៈកម្មការពិនិត្យសម្រេចរួចហើយនោះទេ ។

បណ្ណាធិការ

* * *

បរិវត្តបញ្ហា

## នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

ពីកិរិយានមស្ការថ្វាយបង្គំនៃខ្ញុំព្រះករុណា ចូរមានចំពោះព្រះរតនត្រ័យ គឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ដែលមានព្រះគុណដ៏ប្រសើរឥតមានអ្វីស្មើឡើយ ។

លំដាប់ពីនេះ សូមលើកយកបរិវត្តបញ្ហា ដែលមានក្នុងគម្ពីរលោកន័យមកសំដែង ជាទីសវនាការចំពោះពុទ្ធបរិស័ទទាំងឡាយដូចតទៅនេះ ៖



សេចក្ដីថា: កាលណោះព្រះបរមពោធិសត្វរបស់យើង បានសោយព្រះជាតិក្នុងផ្ទៃនៃនាងសុខុមាលី ជាភរិយានៃធនញ្ជយសេដ្ឋី មាននាមថាធនញ្ជយកុមារ ទៀបនគរឥន្ទបត្តបុរី ក្នុងរជ្ជកាលព្រះបាទធនញ្ជយ-កោរព្យរាជជាមហាក្សត្រគ្រប់គ្រងនគរនោះ ។

លុះធនញ្ជយកុមារមានអាយុ ៧ ឆ្នាំហើយព្រះរាជាកើតសង្ស័យនឹងប្រស្នា ៤ ប្រការ គឺ:

១- ឯកកូបវិតក្កបញ្ហា ទូលអំពីបុគ្គលជីករណ្ដៅដាំសសរហេតុអ្វីក៏លុបដីដែលចេញវិញមិនពេញ ទាល់តែយកដីខាងក្រៅលុបថែមទើបពេញ? ១;

២- ឯកកុម្មណ្ឌផលវិតក្កបញ្ហា ទូលអំពីផ្លែត្រឡាច ឬល្ពៅ ផ្លែវាធំប៉ុនផើង ទងវាតូចប៉ុនខ្សែគោសោះ ហេតុអ្វីក៏មិនដាច់? ១;

៣- ឯកាគត្តិគ្គិវិតក្កបញ្ហា ទូលអំពីស្ត្រីទាំងឡាយ កាលមិនទាន់មានគភ៌បរិភោគអាហារល្មមៗទេ ដល់មានគភ៌ហើយ ហេតុអ្វីក៏បរិភោគអាហារច្រើនឡើងលើសប្រក្រតី? ហើយថែមទាំងស្រេកឃ្លានក៏ខ្លាំងទៀតផង?១

៤- ឯកាហានុលោមវិតក្កបញ្ហា ទូលអំពីពេមចំពើម គេកាត់គោរទៅហើយដុះឡើងសន្សឹមៗ ហើយមិនវែងលើសប្រក្រតីទេ ចុះពុកចង្កាវិញគេកាត់គោរចេញហើយវាដុះឡើងវិញឆាប់ណាស់ ហើយចំរើនវែងផង ព្រោះហេតុអ្វី? ១ ។

បញ្ហាទាំង ៤ យ៉ាងនេះកើតឡើងចំពោះព្រះបាទធនញ្ជយកោរព្យរាជៗ ទ្រង់ស្វែងរកអ្នកប្រាជ្ញរាជបណ្ឌិតក្នុងព្រះនគរអស់៨រាត្រី ដើម្បីឲ្យដោះស្រាយបញ្ហាទាំង៤នេះ, លុះដល់៩ថ្ងៃហើយក៏គ្មាននរណាដឹង គ្មាននរណាដោះស្រាយបានឡើយ ។ វេលានោះទ្រង់មានព្រះរាជបញ្ជាឲ្យធនញ្ជយសេដ្ឋី នាំកុមារទាំង៥០១នាក់ មានធនញ្ជយកុមារជាដើម ឲ្យចូលមកគាល់ព្រះអង្គក្នុងព្រះរាជដំណាក់ដោយរួសរាន់ ។

ធនញ្ជយសេដ្ឋី បាននាំកុមារទាំងអស់ចូលទៅ

តាមព្រះរាជបញ្ហា លុះបាននាំគ្នាថ្វាយបង្គំ អង្គុយគាល់ក្នុងទីអាសនៈដែលរៀបចំទុកដ៏សមគួរហើយ ព្រះរាជាទ្រង់ធ្វើបដិសណ្ឋារៈរាក់ទាក់រីករាយរួចហើយ ក៏ទ្រង់លើកបញ្ហាទី ៤ មកសួរ ធនញ្ជយកុមារឲ្យដោះស្រាយមួយបញ្ហាម្តង ១ ដូច្នេះថា: "ម្នាលធនញ្ជយ-បណ្ឌិត ! បុគ្គលជីករណ្ដៅដាំសសរ គរអាចម៍ដីទុកនៅមាត់រណ្ដៅ ហើយលើកសសរដាំចុះទៅក្នុងរណ្ដៅនោះ យកអាចម៍ដីនោះលុបទៅវិញ ម្ដេចក៏មិនពេញ បើដាំសសរចុះជិតពាក់កណ្ដាលរណ្ដៅហើយ ចុះហេតុអ្វីក៏មិនពេញ ទាល់តែយកដីផ្សេងមកលុបថែមទៀតទើបពេញរណ្ដៅនោះ?" ។

ធនញ្ជយកុមារឆ្លើយដោះស្រាយថ្វាយថា: បពិត្រមហារាជដ៏ប្រសើរ បានជាយកអាចម៍ដីដែលនេះមកលុបវិញមិនពេញរណ្ដៅនោះ ព្រោះបុគ្គលអ្នកដាំសសរញាត់ដីបុកបង្ហាប់ឲ្យណែនតឹងជាងពីមុន ត្រូវថែមដីថ្មីទៀតទើបបានពេញ, ផែនដីឧបមាដូចផ្ទៃក្រោម, រណ្ដៅឧបមាដូចដែនសីមានគរ, ជីករណ្ដៅដូចចែកពល, គំនរដីដូចកងពលជាដំពូក ១ ទ្វេគុណឲ្យច្រើនឡើង, សសរដូចមន្ត្រីធំផុតថ្នាក់ ( គឺនាយករដ្ឋមន្ត្រី ) គ្រង់បុកជ្រុំបង្ហាប់ដូចជារាជទណ្ឌភ័យ ដែលបុកបែនរាស្ត្រទាំងឡាយ មន្ត្រីធំបានចាត់ពលជា ៧ ក្រុម សេនាបតីចែកពល ៧ ក្រុមនោះឲ្យទ្វេគុណឡើងទៅជា ១៤ ក្រុមទៀត ទោះបីធ្វើឲ្យច្រើនទៅដោយកិច្ចក្ដី, ច្រើនទៅដោយទណ្ឌកម្មក្ដី, ធ្វើឲ្យត្រឹមតាមរយៈច្បាប់សព្វអន្លើហើយ មន្ត្រីធំនោះនៅតែមិនចេះពេញប្រាថ្នាទេ លុះតែចាប់យកស្រុកទេសដទៃ ១ ថ្មីដាក់ថែមមកទៀត ទើបបានពេញ (ពោលគឺសេចក្ដីលោភ ដែលតែងកើតឡើងក្នុងសន្ដានអ្នកធំនោះឯង) ធនញ្ជយកុមារ សំដែងអង់គាថាដូច្នេះថា:

ប្រទេសណាមានស្ដេចសោយរាជ្យច្រើនវគ្គ មានអាជ្ញាក៏ច្រើន ប្រទេសនោះចំរើនឡើង នឹងវិនាសទៅដោយឆាប់រហ័សដូចគល់ព្រះអាទិត្យរះឡើង ៧ ដួងក្ដៅណាស់ ដើមឈើ លតាវល្លិទាំងឡាយស្ងោកស្រពោនអស់ហើយ ។ បពិត្រមហារាជ ឯកគូបរិតក្កបញ្ហាប្រស្នាសួរអំពីជីករណ្ដៅដាំសសរ ហើយលុបដីដែលទៅវិញមិនចេះពេញនោះ មានឧបមេយ្យដូច្នេះឯង សូមទ្រង់ជ្រាប ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់ត្រាស់សួរថា: ម្នាលបណ្ឌិត ! ចុះផ្លែត្រឡាចឬល្ពៅផ្លែធំប៉ុនផើង ទងវាតូចប៉ុនខ្សែគោសោះទេ ម្ដេចក៏វាទ្រទ្រង់ផ្លែវាឈ្នះ មិនដាច់ ព្រោះហេតុអ្វី? ចូរវិសជ្ជនាមកមើល !

ព្រះបរមពោធិសត្វអធិប្បាយថា: បពិត្រព្រះសម្មតិទេព សេចក្ដីនេះប្រៀបដូចនគរដ៏សម្បូរស្តុកស្តម្ភ សម្បូរផ្លែទុកដូចជាខេត្តដែនសីមាព្រះនគរ, គ្រាប់វាទុកដូចជារាស្ត្រទាំងឡាយ, សាច់ផ្លែត្រឡាច ទុកដូចជាសេដ្ឋីគហបតី ( ថៅកែ ) ពួកអ្នកមានសម្បត្តិ ទឹងព័ណ៌វា ទុកដូចជាស្រីស្នំក្រមការ រចាំ ល្ខោនមហោរី មហោស្រពផ្សេងៗ ត្រយវាទុកដូចជាព្រះរាជបុត្រា-បុត្រី

នឹងព្រះរាជទេពី, ផ្កាកំទុកដូចជាសមណព្រាហ្មណ៍, ទងកាំទុកដូចជាព្រះមហាក្សត្រ ជាទីពឹងផ្អែករបស់ប្រជានុរាស្ត្រ កាលបើឥតអីរព្រះរាជាហើយ សេនាយោធានឹងអាណាប្រជានុរាស្ត្រទាំងឡាយ នឹងអ្នកមានទ្រព្យធនច្រើនៗ នោះនឹងវិនាសទៅពុំខានឡើយ ព្រោះមានតែព្រះករុណាជាម្ចាស់ជីវិតលើត្បូងមួយព្រះអង្គនោះហើយ ដែលទុកជាជាទងតូចដូចជាខ្សែ តែងទ្រទ្រង់ផ្លែធំប៉ុនផ្លែមិនដាច់, ព្រះអង្គជាក្សត្រទុកជាព្រះមាតាបិតារបស់មហាជនលើផែនដីទាំងមូលនោះឯង ។

ម្យ៉ាងទៀត មានសេចក្ដីពន្យល់ថា: បើប្រទេសណាមានគុណសម្បត្តិ ៥ ប្រការ គឺ:

១- ធនវា មានបុគ្គលអ្នកមានទ្រព្យច្រើន;

២- សោត្ថិយា មានបុគ្គលអ្នកមានសួស្ដីបានដល់សមណព្រាហ្មណ៍;

៣- រាជា មានស្ដេចសោយរាជ្យ;

៤- នទី មានទន្លេឬស្ទឹងល្មមទូក (កប៉ាល់) បើកចេញចូលបាន;

៥- វេជ្ជោ មានគ្រូពេទ្យនឹងមន្ទីរពេទ្យព្យាបាលរោគ ។

ប្រជារាស្ត្រគប្បីនាំគ្នាទៅអាស្រ័យក្នុងប្រទេសនោះចុះ នឹងបានសុខសួស្ដីប្រសើរ ហើយបើរកប្រទេសមានគុណសម្បត្តិទាំង ៥ នេះមិនបានទេ កុំគប្បីទៅអាស្រ័យឡើយមិនបានសុខសួស្ដីទេ ។

បពិត្រមហារាជ ប្រស្នាសួរអំពីផ្លែត្រឡាចឬផ្លែល្ពៅនោះមានឧបមេយ្យដូច្នេះឯង សូមទ្រង់ជ្រាប ។

ព្រះរាជាទ្រង់ព្រះសណ្ដាប់ហើយ មានព្រះរាជហឫទ័យជ្រះថ្លាត្រាស់សួរប្រស្នាទី ៣ តទៅដូច្នេះថា: ម្នាលអ្នកប្រាជ្ញ! ឯកាតក្ដិត្តី ស្រីទាំងឡាយ កាលមិនទាន់មានបុត្រចាប់ផ្ទៃនៅឡើយ តែងបរិភោគអាហារតិចល្មមចំនួនអស់អង្ករ ១ នាឡិ ១ ថ្ងៃៗក៏ឆ្អែតបាន លុះដល់មានបុត្រតាំងនៅក្នុងផ្ទៃហើយ ហេតុអ្វីក៏ទៅជាបរិភោគច្រើនអស់ចំនួនអង្ករ ២ នាឡិ ឬ ៣ នាឡិ ក្នុង ១ ថ្ងៃៗ ហើយបេះតែនៅឃ្លានថែមឡើងទៀតផង តើព្រោះហេតុអ្វី? ចូរអ្នកប្រាជ្ញអធិប្បាយមកមើល!

ព្រះបរមពោធិសត្វអធិប្បាយថ្វាយព្រះរាជាថា: បពិត្រមហារាជ ព្រោះមានបរមតេជោធាតុនេះឡើងខាងក្នុងខ្លាំង បានជាឃ្លានខ្លាំងឡើងជាងពីមុន នេះមានឧបមាដូចព្រះឃ្លាំងដែលមានសួយសារអាករនៅជាប្រក្រតី, ការចំរើនគតិទុកដូចជាចំរើនសួយសារអាករ ដូចមានបទគាថា: អ្នកឯណាបោះបង់ក្ដីទៀងត្រង់ហើយ ទៅសេពគប់នឹងក្ដីមិនទៀងត្រង់ គឺយកសួយច្រើនហួសច្បាប់ដើម, ក្រមច្បាប់នឹងសាបសូន្យទៅ, ការឥតប្រយោជន៍យល់ថាមានប្រយោជន៍, ការមានប្រយោជន៍យល់ថាឥតប្រយោជន៍, សេចក្ដីទាំងពីរនេះនឹងសាបសូន្យទៅពុំខាន ។ អ្នកប្រាជ្ញមានបញ្ញាគប្បីពិចារណាឲ្យឃើញច្បាស់រួចសឹមសេពគប់ ។ ប្រស្នាសួរអំពីស្ត្រីមានគភ៌ជាគំរប់បី មានឧបមេយ្យដូច្នោះឯង ។

ព្រះរាជាទ្រង់ត្រាស់សួរ ឯកាហានុលោមវិតក្កបញ្ហាទី ៤ តទៅដូច្នេះថា: ម្នាលអ្នកប្រាជ្ញ! ចុះរោមចិញ្ចើម

ឃើញ ពោះបើបុគ្គលគេកោរកាត់ចេញក្តី ដកចោលក្តី ឬគេពុំកាត់ពុំដកក្តី រោមចិញ្ចើមនោះក៏ដុះឡើងសន្សឹមៗ ហើយមិនវែងលើសធម្មតាឡើយ ។ ឯពុកចង្កាវិញ មិនដូច្នោះទេ គេកោរកាត់ឬដកចេញទៅ វាខំដុះឡើងវិញយ៉ាងឆាប់រហ័សណាស់ ហើយវែងលើសប្រក្រតីជាដរាប តើព្រោះហេតុអ្វី? ចូរអ្នកប្រាជ្ញអធិប្បាយមកមើល !

ព្រះបរមពោធិសត្វអធិប្បាយថា: បពិត្រមហារាជ ព្រោះថារោមចិញ្ចើមទុកដូចជាសេវកាមាត្យចាស់ៗ ជាន់បុរាណដែលគាប់ព្រះរាជហឫទ័យមានសេចក្តីស្និទ្ធស្នាលនឹងរាជបុង្គន ហើយជាអ្នកប្រាសចាកក្តីលោភចង់បានហួសហេតុ ជាអ្នកមិនមានអគតិទាំង ៤ ឡើយ ។

ឯពុកចង្កាទុកដូចជាអាមាត្យទើបនឹងចូលបម្រើថ្មីៗ បានយសស័ក្តិជាធំ ហើយឡើងមានៈឆ្មើងឆ្មើរលោភរឹបជាន់រាស្ត្រអាងខ្លួនជាអ្នកគាប់គួរនឹងព្រះចៅ ប្រកបដោយឆន្ទាគតិ លំអៀងដោយសេចក្តីស្រឡាញ់ក៏មាន, ទោសាគតិ លំអៀងដោយចងសំអប់ក៏មាន, ភយាគតិ លំអៀងដោយភ័យខ្លាចក៏មាន, មោហាគតិ លំអៀងដោយល្ងង់ខ្លៅក៏មាន, នាំឲ្យប្រព្រឹត្តហួសក្រមច្បាប់ ។ រហូតដល់ធ្វើខ្លួនឯងឲ្យធ្លាក់បុណ្យស័ក្តិ ព្រោះតែប្រកបដោយអគតិទាំង ៤ នោះកើតឡើងក្នុងសន្តានអាមាត្យទាំងនោះឯង ។

បញ្ហាសួរអំពីរោមចិញ្ចើមនឹងពុកចង្កាមានឧបមេយ្យដូច្នោះឯង សូមទ្រង់ជ្រាប ។

ព្រះបាទធនញ្ជយកោរព្យរាជទ្រង់ព្រះសណ្តាប់បញ្ហាព្យាករណ៍ ព្រះបរមពោធិសត្វហើយ ទ្រង់មានព្រះរាជហឫទ័យសោមនស្សរីករាយ ទ្រង់បន្លឺនូវសទ្ទសញ្ញាថា: សាធុ! សាធុ! ប្រពៃហើយ! ត្រូវណាស់ហើយ! ។

លំដាប់ពីនោះ ព្រះបរមពោធិសត្វសំដែងពីច្បាប់អ្នកតូចចូលទៅបំរើអ្នកធំដូច្នេះថា: ច្បាប់អ្នកតូចមាន ៥ យ៉ាង គឺ:

១- ត្រូវមានសភាពស្លូតត្រង់ស្មោះចំពោះនឹងលោកអ្នកធំ;

២- ត្រូវដឹងដំណឹងផ្សេងៗនឹងលោកជាធំ;

៣- ត្រូវពោលពាក្យសច្ចៈ កុំកុហកឲ្យសោះ;

៤- ត្រូវឧស្សាហ៍បំរើលោក កុំខ្ជិលឲ្យសោះ;

៥- ត្រូវសំដែងសិល្បសាស្ត្រដំរិះវិជ្ជាឲ្យប្រាកដដល់លោកជាធំ ។

ការប្រព្រឹត្តតាមច្បាប់អ្នកតូចទាំង ៥ ប្រការនេះ ទើបនៅអាស្រ័យជ្រកកោននឹងលោកអ្នកធំបានសុខសួស្តី ប្រកបបុណ្យស័ក្តិនឹងកិត្តិគុណផ្សេងៗ ដូចមាននិពន្ធគាថាដូច្នេះថា:

បើបំរើព្រះមហាក្សត្រ ត្រូវឲ្យមានសភាពពិតព្រះមហាក្សត្រគាប់ព្រះរាជហឫទ័យ នឹងវត្ថុអ្វីៗ ត្រូវផ្គាប់ដោយវត្ថុនោះៗ ។

ម្យ៉ាងទៀតថា: បើត្រូវការយកចិត្តទុកដាក់ចំពោះអ្នកលោភត្រូវយកចិត្តដោយឲ្យប្រយោជន៍, យកចិត្តអ្នករបឹងរឹងរូស ត្រូវធ្វើអញ្ជលីកម្ម, យកចិត្តមនុស្សល្ងង់

ត្រូវតែចាក់បណ្ដោយតាម, យកចិត្តអ្នកប្រាជ្ញ ឬស្ដេច ត្រូវធ្វើតាមសភាពពិតត្រង់ ។ មនុស្សមានពុតត្បុត មានលក្ខណៈសំគាល់ដូច្នេះ ជានេ បេសយេ ភច្ចេ បើចង់ដឹងពុតអាមាត្យត្រូវដឹងក្នុងវេលាប្រើ ។ ពន្ធវេ ភយេ គមេ បើចង់ដឹងពុតញាតិត្រូវដឹងក្នុងវេលាមានភ័យ ។ អាបទាសុ តថា មិត្តេ ចង់ដឹងពុតមិត្តសំឡាញ់ត្រូវដឹងក្នុងវេលាមានអន្តរាយ គឺទុក្ខធុរៈកើតឡើង ។ ទារញ្ច វិភវក្ខយេ ចង់ដឹងពុតប្រពន្ធត្រូវដឹងក្នុងវេលាអស់ទ្រព្យសម្បត្តិ (គឺក្រដល់មក) ។ បិដ្ឋិតោ កំ នវេសេយ្យ បើហាលថ្ងៃត្រូវឲ្យបែរខ្នងទៅរកព្រះអាទិត្យ ។ កុច្ឆិនាវហុតាសនំ បើអាំងភ្លើងត្រូវបែរផ្ទៃទៅរកភ្លើង ។ សាមិកំ សព្វភាវេន បើសេពគប់នឹងលោកអ្នកធំត្រូវសេពនឹងពាក្យសត្យ គឺសភាពពិតត្រង់ ។ បរលោកំ អមោហវា បើសេពនឹងបរលោកនាយត្រូវឲ្យសេពនឹងធ្វើទាន រក្សាសីល ចំរើនមេត្តាភាវនា កុំធ្វើអំពើបាបលាមកឲ្យសោះ ។

ម្យ៉ាងទៀតថា: សេចក្ដីព្យាយាមបំរើជាសត្រូវខាងដើមបន្តិច, តែគង់បានជាមិត្តវិញ, សេចក្ដីខ្ជិលជាមិត្តបានស្រណុកខាងដើមបន្តិច តែគង់ប្រែជាសត្រូវវិញ, វិជ្ជាសាស្ត្រ ដើមដំបូងដូចជាពិស ប៉ុន្តែត្រឡប់មកជាមិត្តវិញ, សេចក្ដីធ្វេសប្រហែសហាក់ដូចជាមិត្តមុនដំបូង តែគង់ប្រែជាពិសវិញ ។

សេចក្ដីអធិប្បាយថា: ការព្យាយាមបំរើលោកអ្នកធំដំបូងឡើយត្រូវនឿយព្រួយដូចជាពិបាកណាស់ ប៉ុន្តែគង់នឹងបានសេចក្ដីសុខជាខាងក្រោយពុំខានឡើយ ។

ឯមនុស្សមិនឧស្សាហ៍ ដំបូងហាក់ដូចជាស្រណុកចិត្ត ប៉ុន្តែគង់ក្លាយទៅជាទុក្ខខាងក្រោយពុំខាន, អ្នករៀនជំរះវិជ្ជាផ្សេងៗនោះ ដំបូងហាក់ដូចជានឿយព្រួយខ្លាំងណាស់ តែគង់នឹងបានសុខចំរើនជាខាងក្រោយវិញ, អ្នកធ្វើបាបលាមកដំបូងហាក់ដូចជាស្រណុកសុខសប្បាយ ដល់ក្លាយខ្លួនទៅក្នុងចតុរាបាយក៏រងទុក្ខក្រៃពេកជាខាងក្រោយពុំខាន ។

ម្យ៉ាងទៀត មានបទគាថាដូច្នេះថា: នត្ថិ វិជ្ជាសមំ ធនំ ទ្រព្យអ្វីនឹងស្មើដោយវិជ្ជាមិនមាន, នត្ថិ ព្យាធិ សមោ អរិ សត្រូវអ្វីនឹងស្មើដោយព្យាធិមិនមាន, នត្ថិ អត្តសមំ បេមំ ស្រឡាញ់អ្វីនឹងស្មើស្រឡាញ់ខ្លួនមិនមាន, នត្ថិ កម្មសមំ ពលំ កំឡាំងអ្វីនឹងស្មើកំឡាំងកម្មផលបុរាណមិនមានឡើយ ។

ព្រះមហាក្សត្រាធិរាជ ទ្រង់ព្រះសណ្ដាប់ហើយ ទ្រង់មានព្រះសោមនស្សជ្រះថ្លា ទ្រង់លាន់ព្រះឧក្ការថា: យើងបើមានទុក្ខភ័យយ៉ាងណាក្ដី ក៏ត្រូវប្រកបដោយអង្គ ៤ ប្រការនេះ គឺ:

១- ពោលវាចាកុំកោតញញើត ត្រូវក្លាហានជាធម្មតា;

២- ពោលពាក្យប្រកបដោយរិទ្ធិ ជាធម្មតា;

៣- ពោលពាក្យធំៗ ច្បាស់ៗ ជាធម្មតា;

៤- ពោលពាក្យទៀងទាត់ មិនឃ្លៀងឃ្លាត ជាធម្មតា;

៩- ពោលពាក្យពីរោះផ្អែមល្ហែម ហើយប្រកបដោយច្បាប់ ជាធម្មតា ទើបធ្វើជាមហាក្សត្រិយ៍គ្រប់គ្រងសីមាបាន ។

បន្ទាប់ពីនេះមកទៀត ព្រះបរមពោធិសត្វ សំដែងអានិសង្សមេត្តាចិត្តមាន ១១ យ៉ាង គឺ:

១- សុខំ សុបតិ ដេកលក់ស្រួល;

២- សុខំ បដិពុជ្ឈតិ ភ្ញាក់ឡើងក៏ស្រួល;

៣- ន បាបកំ សុបិនំ បស្សតិ មិនយល់សប្តិអាក្រក់;

៤- មនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់នៃមនុស្សទាំងឡាយ;

៥- អមនុស្សានំ បិយោ ហោតិ ជាទីស្រឡាញ់រាប់អានរបស់អមនុស្សទាំងឡាយ;

៦- ទេវតា រក្ខន្តិ ទេវតាតែងថែរក្សាការពារសត្រូវ;

៧- នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ ភ្លើងមិនឆេះ សត្វអាសិរពិសមិនហ៊ានចឹក ទាំងមិនមានរបួសដោយគ្រឿងសស្ត្រាវុធ;

៨- ចិត្តំ សមាធិយតិ ចិត្តតែងតាំងនៅនឹងមិនអន្ទះអន្ទែង;

៩- មុខវណ្ណោ វិប្បសីទតិ មានសម្បុរទឹកមុខភ្លឺថ្លាជានិច្ច;

១០- អសម្មូឡ្ហោ កាលំ ករោតិ មិនវង្វេងក្នុងវេលាធ្វើមរណកាល;

១១- ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ បើមិនទាន់បានលុះធម៌ជាន់ខ្ពស់ គង់នឹងបានសមាបត្តិ, ពេលដែលច្យុតិក៏បានឡើងទៅឧប្បត្តិក្នុងព្រហ្មលោកនាយ ។

រួមជា ១១ ប្រការ បុគ្គលគប្បីចំរើនមេត្តាព្រហ្មវិហារដើម្បីយកផលានិសង្សទាំង ១១ នេះ នឹងបានសុខសួស្តីក្សេមក្សាន្តក្នុងឥធលោក និងបរលោកមែនពិត ។

ព្រះបរមពោធិសត្វទ្រង់សំដែងបរិតក្កបញ្ហាទាំង ៤ ប្រការចប់វេលាណាហើយ សំឡេងពរសព្ទសាធុការនៃទេវតានិងមនុស្សទាំងឡាយលាន់ឮឡើងកក្រើករំពឹកហាក់ដូចជាទីទ្រុឌចុះនៃក្រឡាមហាប្រថពី ព្រមទាំងគ្រឿងសក្ការបូជាដ៏ច្រើនពន្ទឹកមហិមាគណនាពុំបានជាអស្ចារ្យក្រៃពេកហោង ។

សំដែងមកអំពីរឿង ព្រះបាទធនញ្ជយកោរព្យរាជ ចោទរិតក្កបញ្ហា ៤ ប្រការ ចំពោះព្រះបាទធនញ្ជយ-បរមពោធិសត្វ ។ ព្រះបរមពោធិសត្វបានឆ្លើយដោះស្រាយថ្វាយចប់ទាំង៤ប្រការហើយ សំដែងពីប្រទេសប្រកបដោយគុណសម្បត្តិ ៩ ប្រការ សំដែងច្បាប់អ្នកគួរបំរើអ្នកធំ ៩ ប្រការ និងអង្គរបស់លោកអ្នកធំ ៩ យ៉ាង រហូតដល់អានិសង្សមេត្តាចិត្ត ១១ យ៉ាង ជាទីបំផុត គួរដល់កាលវេលាហើយ សូមសម្មតថាចប់ធម៌ទេសនាប៉ុណ្ណោះ សូមឲ្យព្រះពុទ្ធសាសនា និងពុទ្ធបរិស័ទអ្នកកាន់ព្រះពុទ្ធសាសនាទាំងឡាយបានចំរើនរុងរឿង

ឡើងក្នុងកម្ពុជរដ្ឋទាំងមូល នឹងសូមឲ្យប្រទេសជាតិ មាតុភូមិ សាសនា នឹងមហាក្សត្រិយ៍ មានជ័យជំនះ ឈ្នះមារសត្រូវទាំងអស់ហើយតាំងនៅក្នុងសុខភាព ដរាបដល់បានសម្រេចព្រះនិព្វានជាអវសាន កុំបីឃ្លៀងឃ្លាតឡើយ !

ព្រះគ្រូបុរត្ថិមវង្សី អ៊ូ-ប៊េវ

x x

x

# សម្មាសាមគ្គី នឹង មិច្ឆាសាមគ្គី

ជនជាតិខ្មែរយើង ទាំងបព្វជិតនឹងគ្រហស្ថ សុទ្ធសឹងតែស្គាល់ពាក្យថា “សាមគ្គី” ស្ទើរតែគ្រប់គ្នាទាំងអស់ ប៉ុន្តែមានខ្លះយកសាមគ្គីទៅប្រើក្នុងផ្លូវត្រូវ ខ្លះយកទៅប្រើក្នុងផ្លូវខុស ថែមទាំងនាំឲ្យសាបសូន្យប្រយោជន៍របស់ខ្លួនទៀត ។

សម្មាសាមគ្គី-សាមគ្គីត្រូវ-ដូចជាខំប្រឹងប្រែងស្វះស្វែងប្រមូលគ្នីគ្នារៀនសូត្រចំណេះវិជ្ជាគ្រប់យ៉ាង ទាំងគតិលោក-គតិធម៌ ឬរកស៊ីធ្វើការខាងពាណិជ្ជកម្ម កសិកម្ម ឧស្សាហកម្ម ។ល។ មិនមានឥច្ឆាប្រណែនឈ្នានីសដល់គ្នានឹងគ្នា បើឃើញជាតិជាមួយគ្នាបានខ្ពង់ខ្ពស់ ជួយត្រេកអរតាម ៗ ឯអ្នកខ្ពង់ខ្ពស់វិញ ក៏មិនព្រងើយកន្តើយ ឬស្រវឹងក្នុងយសស័ក្តិ ទ្រព្យសម្បត្តិ តែងតែមានចិត្តករុណាមេត្តាទៅកាន់អ្នកតូចទាបជាងខ្លួនជាដរាប ហើយការពារមិនឲ្យជាតិដទៃមើលងាយបាន ចេះស្រឡាញ់គ្នា ចងបាច់គ្នាជាដុំឡើង សាមគ្គីបែបនេះនាំឲ្យចំរើនគ្រប់ផ្លូវ ៗ ខាងគតិលោកនាំឲ្យជាតិយើងបានចំរុងចំរើន ជាទីអែងដល់ជាតិដទៃ គេមិនហ៊ានមើលងាយ មានតបះឈ្នះអស់សត្រូវផ្សេងៗ ។ បើប៉ែកខាងគតិធម៌វិញ នឹងនាំឲ្យសាសនាចំរុងចំរើនរុងរឿងដោយកិច្ចបដិបត្តិតាមផ្លូវត្រូវ ព្រោះមានចំណេះវិជ្ជាគ្រប់ផ្លូវ ស្គាល់កិច្ចបដិបត្តិគ្រប់យ៉ាង ជាទីអែងកោតញញើតអំពីអ្នកកាន់សាសនាដទៃៗ ។

មិច្ឆាសាមគ្គី - សាមគ្គីខុស - ដូចជាខំប្រមែប្រមូលគ្នីគ្នាមិនរៀនសូត្រ ដោយប្រកាន់ថាៈ គេរៀនអក្សរឥឡូវនេះ មិនមានក្តារខៀន-ទឹកលុប ឬរៀនមិនស្គាល់ខុសត្រូវ ខ្លះបបួលគ្នាមិនរៀនធម៌ប្រែ មិនជឿព្រះត្រៃបិដក មិនធ្វើតាមរបៀបរបបដែលលោកអ្នកប្រាជ្ញខាងពុទ្ធសាសនបណ្ឌិត្យរៀបរៀងមក បើមានកូន ឬមានចៅប្អូនមិនហ៊ានឲ្យដើរទៅរៀនសូត្រទេ ក្រែងរៀនពានទៅលើធម៌ខុស ខំធ្វើតែតាមទំនៀមទម្លាប់ខុសរបស់ម៉ែឪគ្រូបាធ្យាយដែលមិនបានរៀនសូត្រ ស៊ីបពួជីវិតថា បើម៉ែឪចុះនរកក៏សុខចិត្តចុះនរកតាមដែរ មានខ្លះដល់ពេលចលកិច្ចក៏លាន់មាត់ថាៈ “ធ្វើម្តេចឯងខ្មែរល្ងង់យ៉ាងហ្នឹង” ហើយបើឃើញគេរៀនសូត្រលបលួចនិយាយឲ្យគេថា “រៀនគ្រាន់តែស៊ីញោលក់ដី” លុះគេរៀនចេះបានធ្វើជី ធ្វើលោក ឬខ្លះមិនបានធ្វើអ្វីនឹងគេ វិលត្រឡប់មកធ្វើស្រែចម្ការឯស្រុកកំណើតរបស់ខ្លួនវិញ ក៏លបថាឲ្យគេទៀត តែបើដល់ពេលត្រូវការ

ក្នុងក្រសួងរាជការ ឬត្រូវការធ្វើសំបុត្រស្នាមអ្វីម្តងៗ ធ្វើខ្លួនឯងមិនកើត គោងទៅពឹងអ្នករៀនឲ្យគេធ្វើឲ្យ ដល់គេដេញពុតទាន់ គេមិនធ្វើឲ្យ ខឹងនឹងគេ ថាឲ្យគេទៀតថា "ជាតិខ្មែរសុទ្ធតែយ៉ាងហ្នឹង បានរៀនសូត្របេះដូងបន្តិចបន្តួចពឹងមិនបាន" ឱ! ពុទ្ធោអើយ កាលដែលគ្នាចំប្រឹងប្រែងស្វះស្វែងរៀនសូត្រ ទម្រាំតែបានចេះដឹងប៉ុណ្ណេះ ស្ទើរហិនហោចទ្រព្យសម្បត្តិម៉ែឪអស់ទៅហើយ ឥតមានអ្នកណាមួយឡើយជួយទំនុកបំរុងផ្គងផ្តើមសោះ មានតែពាក្យផ្តួនា ឈ្នានីសគ្នាថែមទៀត ដូច្នេះហើយដែលហៅថាប្រព្រឹត្តសាមគ្គីខុស នាំឲ្យខ្លួនរឹតតែល្ងង់ទៅ និងនាំឲ្យជនបរទេសមើលងាយធ្វើបាបឲ្យថោកទាបជាតិព្រមទាំងបានសេចក្តីទុក្ខលំបាកជាច្រើនផង ។

សាមគ្គីទាំងពីរយ៉ាង ដែលពោលមកខាងលើនេះ មានអំណាចប្រហែលគ្នា តែមួយខាងផ្លូវត្រូវ មួយខាងផ្លូវខុស ។ សាមគ្គីត្រូវ មានប្រយោជន៍ធំទូលាយវែងឆ្ងាយប៉ុណ្ណា សាមគ្គីខុសក៏នាំឲ្យសាបសូន្យប្រយោជន៍ធំប៉ុណ្ណោះដែរ ។

ហេតុនេះគួរជនជាតិខ្មែរយើងលះបង់សាមគ្គីខុសនោះចោលចេញឲ្យផុតស្រឡះពីសន្តានទៅ, នាំគ្នាប្រព្រឹត្តតែសាមគ្គីត្រូវ ដើម្បីនាំជាតិរបស់យើងឲ្យមានដំណើរលឿនទៅកាន់វឌ្ឍនធម៌ និងអារ្យធម៌ស្មើស្មានឹងអារ្យជាតិដទៃទៀត បើយើងនៅតែនាំគ្នាប្រកាន់យកតែខាងផ្លូវខុសដូចពោលហើយ មិនដឹងជាបាននរណាមកជួយលើកដំកើងយើងផុសឡើងបានទេ មានតែផ្លូវសាបសូន្យមួយមុខប៉ុណ្ណោះឯង ។

សៅ-ចេស

x x
x

## ការសិក្សាក្នុងប្រទេសជប៉ុន (តចប់)

## បឋមសិក្សា.

ក្នុងព្រះរាជអាណាចក្រជប៉ុន មានសាលារៀនបឋមសិក្សាច្រើនជាទីបំផុត ។ វត្ថុបំណងរបស់សាលារៀនបឋមសិក្សាដែលរដ្ឋាភិបាលបានប្រកាសមកហើយនោះមានសេចក្តីដូចតទៅនេះគឺ៖ "ក្នុងការបណ្តុះបណ្តាលក្មេងឲ្យចំរើនដោយវ័យវុឌ្ឍិនិងគុណវុឌ្ឍិ ដើម្បីនឹងបានជាមូលដ្ឋានខាងចរិយា (គឺសណ្តាប់ធ្នាប់) និងខាងផ្លូវសិក្សារបស់ប្រទេសជាតិនោះ ជាការចាំបាច់យ៉ាងទីបំផុតដែលត្រូវបណ្តុះវិជ្ជាការ និងសិល្បសាស្ត្រដល់ពួកក្មេងដើម្បីជាប្រទីបពន្លឺសម្រាប់ឆ្លុះមើលផ្លូវដំណើរជីវិតរបស់គេក្នុងអនាគត ។

ហេតុនោះសាលារៀនបឋម ទើបគេចាត់ទុកជាកន្លែងអប់រំដែលជាមូលដ្ឋាននៃការសិក្សារបស់ប្រជារាស្ត្រ ក្នុងការនេះរដ្ឋាភិបាលបានចេញបទបញ្ញត្តិ និងរបៀបបទ ហាមប្រាមបង្គាប់បញ្ជាក្នុងការចាត់តាំងនិងការសាងគ្រឿងឧបករណ៍របស់សាលារៀនបឋមសិក្សា ក្នុងប្រទេសជប៉ុនមានសាលាបឋមសិក្សា ២ ប្រភេទគឺៈ សាលារៀនបឋមសិក្សាសាមញ្ញ ដែលមានការបង្ខំឲ្យ

រៀនតាមរបៀបមេរៀនអស់រយៈវេលាកំណត់ ៦ ឆ្នាំ និងសាលារៀនបឋមសិក្សាថ្នាក់ខ្ពស់ ឬហៅថាបឋមសិក្សាវិសាមញ្ញ ដែលមានមេទន្ទេញតាំងពី ២ ឆ្នាំ ដល់ ៣ ឆ្នាំ សាលារៀនបឋមវិសាមញ្ញនេះ ទទួលបានតែចំពោះអ្នករៀនដែលបានសម្រេចថ្នាក់បឋមសិក្សាដែលគេបង្ហឹរួចមកហើយ, ក្មេងជប៉ុនគ្រប់គ្នាដែលមានអាយុតាំងពី ៦ ដល់ ១៤ ឆ្នាំ នៅក្នុងបទបញ្ញត្តិបឋមសិក្សា ដែលរដ្ឋាភិបាលបង្ខំឲ្យរៀន ឯបឋមសិក្សានេះ រដ្ឋាភិបាលកណ្តាលបានប្រគល់អំណាចឲ្យរដ្ឋាភិបាល តាមខេត្តឬទេសបាលជាអ្នកចាត់ការធ្វើ ។

ហេតុនោះសាលារៀនបឋមសិក្សាផ្សេងៗ ដែលមាននៅក្នុងព្រះរាជអាណាចក្រជប៉ុន អាចតាំងនៅបានជាស្ថាពរយូរអង្វែងបានយ៉ាងមាំមួន ក៏ដោយការអាស្រ័យថវិការបស់ទេសបាល ប្រាក់ទំនុកបំរុងដែលរដ្ឋាភិបាលចែកឲ្យអំពីថវិកាជាតិ បើយើងធៀបមើលការចំរើននៃការសិក្សាក្នុងប្រទេសជប៉ុន នឹងប្រទេសអឺរ៉ុបហើយ ក៏នឹងឃើញថា ការបឋមសិក្សារបស់ជប៉ុនបានចំរើនលឿនយ៉ាងទីបំផុត មិនចាញ់ប្រទេសដែលចំរើនដោយការសិក្សាសោះឡើយ ។ ការពង្រីកបឋមសិក្សារបស់ជប៉ុន ហើយក្មេងជប៉ុនដែលបានចូលទៅសិក្សាមានចំនួនច្រើនឡើងយ៉ាងខ្ពស់គឺ៩៩% ក្រសួងសិក្សាធិការជប៉ុនបានគ្រួតស្ថិតិក្នុងព.ស.២៤៨០ ឃើញមានចំនួនក្មេងដែលបានចូលទៅសិក្សាក្នុងសាលាបឋមសិក្សាមាន ៩៩.៩៤. ការបរិមាណក្មេងជប៉ុនដែលបានសម្រេចក្នុងបឋមសិក្សាមានកំរិតយ៉ាងច្រើនគួរឲ្យជ្រះថ្លាពន់ពេកនេះ ព្រោះចំនួនពលរដ្ឋបានទ្វេឡើងក្នុងមួយឆ្នាំជិតដល់មួយលាននាក់ ហើយក៏ជ្រៀតបៀតគ្នានៅតែខាងប្រទេសរបស់ខ្លួនដែលជាកោះចង្អៀតម្យ៉ាង ម្យ៉ាងទៀតមាតាបិតាជប៉ុនមាននិស្ស័យចិត្តចង់ឲ្យកុលបុត្រកុលធីតារបស់ខ្លួនមានចំណេះវិជ្ជា ទើបខំព្យាយាមប្រតិបត្តិតាមបទបញ្ញត្តិបឋមសិក្សាយ៉ាងពេញទី ហើយខំព្យាយាមបញ្ជូនកុលបុត្រកុលធីតាឲ្យចូលសាលារៀនបឋមសិក្សា ដោយឥតមានគិតដល់ឧបសគ្គបែបណាសោះឡើយ ។

គ្រប់ខេត្តក្នុងព្រះរាជអាណាចក្រជប៉ុន បើទុកណាជាទីនោះនៅឆ្ងាយពីទីក្រុងឬរាជធានីធំៗក៏ដោយចុះ តែងតែមានសាលារៀនបែបប៉ាប់លិគស្គូលជាដរាប ហើយទេសបាលជាអ្នកឧបត្ថម្ភសាលារៀនបែបនេះឲ្យបានចំរើនកើនឡើងជាលំដាប់ ។

រដ្ឋាភិបាលបានចេញច្បាប់បង្គាប់នឹងជាក់របៀបការដែលទាក់ទងនឹងសាលាបឋមសិក្សានេះ ក្រសួងសិក្សាធិការជាអ្នករៀបចំមេសូត្រ (មេទន្ទេញ) ថ្នាក់បឋមសិក្សា ហើយចាត់បោះពុម្ពសៀវភៅបែបរៀនផ្សេងៗគឺបែបរៀនចរិយា ភាសាជប៉ុន លេខគណិត ប្រវត្តិសាស្ត្រជប៉ុន ភូមិសាស្ត្រ និងវិចិត្រសិល្បកម្ម គ្រូសាលារៀនបឋមនឹងគ្រឿងឧបករណ៍ក្នុងការរៀននៅក្នុងទីក្រុងផ្សេងគ្នាអំពីសាលារៀនដែលស្ថិតនៅតាមជនបទ ។ ឯសាលារៀនថ្នាក់បឋមសិក្សា ដែលស្ថិតនៅ

ក្នុងទីក្រុងធំៗ គេច្រើនសាងឡើងដោយឥដ្ឋឬស៊ីម៉ង់ ចំណែកឯសាលារៀនដែលនៅតាមជនបទនានានោះ គេធ្វើដោយឈើ សាលារៀនដែលនៅក្នុងទីក្រុងសឹងមានគ្រឿងឧបករណ៍គ្រប់គ្រាន់ ដូចយ៉ាងបន្ទប់សម្រាប់ប្រជុំ បន្ទប់គ្រូ ។ល។ និងបន្ទប់កាយបរិហារពិសេសដែលចាត់សម្រាប់ក្មេង ចំពោះតែក្មេងណាដែលមានសុខភាពមិនសម្បូណ៌ ឯសាលារៀនដែលនៅតាមជនបទ ឬ សាលារៀនខ្លះដែលតាំងនៅលើខ្នងភ្នំ ឬ លើកោះ សាលារៀនទាំងនោះមានតែបន្ទប់រៀនមួយៗប៉ុណ្ណោះទេ ។

ការសិក្សាតាមរបៀបថ្មីរបស់ជប៉ុនមានសេចក្ដីចំរើនយ៉ាងសម្បើមក្នុងរយៈវេលាប្រហែល ១៤ ឆ្នាំប៉ុណ្ណោះ ព្រោះសាលារៀនខ្លះបានទទួលយកទ្រឹស្ដីខាងរបៀបការសិក្សាបែបថ្មី មកផ្សំប្រើជាមួយនឹងទ្រឹស្ដីរបស់ជប៉ុន សាលារៀនដែលមានវិធីបង្ហាត់តាមទ្រឹស្ដីរបៀបការសិក្សាថ្មីនេះ បានទទួលនូវសេចក្ដីសរសើរអំពីប្រជាជនយ៉ាងច្រើន ហើយបានផ្សាយពេញព្រះរាជ-អាណាចក្រជប៉ុន សាលារៀនបឋមសិក្សាថ្នាក់ខ្ពស់ ឬ បឋមសិក្សាវិសាមញ្ញ មានអ្នករៀនបានសម្រេចវិជ្ជាតាមរបៀបបឋមសិក្សាសាមញ្ញ ប្រមាណ ៦០% ហុកសិបភាគរយនោះ បានជាទីនិយមរបស់ប្រជាជនទូទៅ, សិស្សដែលចូលសាលារៀនមធ្យមសិក្សាបាននោះ លុះត្រាតែបានរៀនសម្រេចតាមរបៀបសាលារៀនបឋមសិក្សាសាមញ្ញមកសិន ទើបចូលបាន របៀបទាំងនេះជាមេទន្ទេញរបស់សាលារៀនបឋមជាន់ខ្ពស់ ឬ បឋមវិសាមញ្ញ បានជាគេកំណត់ទុកតាំងពី ២ ឆ្នាំទៅដល់ ៣ ឆ្នាំជាដំបូង ។ សាលារៀនបឋមសិក្សាថ្នាក់ខ្ពស់ដែលមានរបៀបនឹងចាត់ការល្អ ព្រោះមានការសម្ពន្ធជាមួយនឹងឧស្សាហកម្មរបស់ទីនោះ ទើបបានទៅជាស្ថានហ្វឹកហាត់ឧស្សាហកម្មប្រចាំតំបន់ដែលមានសមត្ថភាពល្អក្នុងការហ្វឹកពួកយុវជនក្នុងកន្លែងនោះៗ ឲ្យបានចំរើនឡើង ។

ទូទៅក្នុងអាណាចក្រជប៉ុនតាមការស្ថិតិចុងក្រោយបំផុតក្នុង ព.ស. ២៤៧៨ ជប៉ុនមានសាលារៀន ៧០៧៨ សាលា, សាលារៀនបឋមអាជីវកិច្ចមានចំនួនដូចគ្នានឹងសាលារៀនបឋមសិក្សាថ្នាក់ខ្ពស់ ១៧២ សាលា បើសរុបទាំងអស់ទៅ សាលារៀនបឋមសាមញ្ញ និងសាលារៀនបឋមអាជីវកិច្ចរបស់ជប៉ុនទាំងអស់មាន ២៥.៧៧០ សាលា ចំនួនអ្នករៀនដែលកំពុងរៀននៅថ្នាក់បឋមសិក្សា មានដូចនេះគឺ៖ សាលារៀនបឋមសាមញ្ញមាន ៩.៦១២.៥៦៤ នាក់ សាលារៀនបឋមជាន់ខ្ពស់ ឬ បឋមវិសាមញ្ញមាន ១.៦១៩.៥១២ នាក់ បើបូកសរុបទាំងអស់ អ្នករៀនដែលនៅកំពុងសិក្សាក្នុងថ្នាក់បឋមសិក្សានោះ មានចំនួនទាំងអស់ ១១.២៣២.០៧៦ នាក់ ។

ចាប់តាំងពីផ្ដើមខាងដើមរជ្ជកាលស្ដេច "មេអ៊ិយ៉ិ" ព.ស. ២៤១១-២៤៥៥ ជាដើមមក រដ្ឋាភិបាលបានយកចិត្តទុកដាក់ក្នុងការដែលនឹងអប់រំពលរដ្ឋ

ជប៉ុនឲ្យមានចំណេះវិជ្ជាសម្រេចជាន់បឋមសិក្សាយ៉ាងពេញទី ។ សាលារៀនបឋមទើបក្លាយទៅជាទីសំណាក់ការសិក្សាយ៉ាងសំខាន់ ដែលហុចឲ្យចំណេះវិជ្ជានឹងសុវត្ថិភាពដល់ប្រទេសជប៉ុន ។

ការដែលបឋមសិក្សារបស់ជប៉ុនបានចំរើនអស្ចារ្យយ៉ាងនេះក៏ព្រោះបទបញ្ញត្តិស្តីអំពីការបឋមសិក្សាយ៉ាងបង្ខំរបស់ជប៉ុនទោះមានអំណាចសក្តិសិទ្ធិណាស់ ឯពលរដ្ឋនោះសោតក៏និយមការសូត្ររៀនយ៉ាងពិតប្រាកដមែនៗ ។

## មធ្យមសិក្សា

សាលារៀនមធ្យមសិក្សាក្នុងប្រទេសជប៉ុនមាន ២ ប្រភេទ គឺសាលារៀនមធ្យមដែលបង្ហាត់វិជ្ជាសាមញ្ញ នឹងសាលារៀនមធ្យមវិសាមញ្ញ ឬមធ្យមតិកនិក ។ សាលារៀនមធ្យមក្នុងប្រទេសជប៉ុន មិនចាត់ជាសហសិក្សាដូចសាលារៀនបឋមសិក្សាទេ គេចាត់ជាសាលារៀនមធ្យមសម្រាប់អ្នករៀនប្រុសហៅថា "មិដឹលស្គូល" នឹងសាលារៀនមធ្យមស្រីហៅថា "ហៃស្គូល" ក្រៅអំពីនេះមានសាលារៀនជំនាងមធ្យមវិសាមញ្ញដែលបង្ហាត់វិជ្ជាខាងផ្នែកជាងតែម្យ៉ាង ។

## សាលារៀនមិដឹលស្គូល

សាលារៀនមធ្យមសាមញ្ញ ឬមិដឹលស្គូល ជាកន្លែងសិក្សាដែលអាចឲ្យផលគឺសេចក្តីចេះខាងសាមញ្ញសិក្សាដល់ក្មេងប្រុស ។ អប់រំក្មេងប្រុសដែលនៅក្នុងសណ្តាប់ធ្នាប់របស់ជាតិ មេរៀនរបស់សាលារៀនមធ្យមសិក្សាសាមញ្ញមានកំណត់ ៥ ឆ្នាំ ហើយទទួលចំពោះតែអ្នករៀនណាដែលបានរៀនសម្រេចវិជ្ជាក្នុងសាលារៀនបឋមសិក្សាមកហើយ ។ ឯវិជ្ជាដែលគេបង្រៀនក្នុងសាលារៀនមធ្យមដូចនេះគឺ— ចរិយា. នាទីរបស់ពលរដ្ឋ (ភាសារបស់ជប៉ុន) វណ្ណគតិចិន, ប្រវត្តិសាស្ត្រ, ភូមិសាស្ត្រ, (ភាសាបរទេស), គណិតសាស្ត្រ វិទ្យាសាស្ត្រ វិជ្ជាតិកនិកជាងគំនូរ វិជ្ជាតន្ត្រី, ហ្វឹកហាត់ការងារនឹងកាយបរិហារក្នុងថ្នាក់មធ្យមឆ្នាំទី ៤ នឹងឆ្នាំទី ៥ អ្នករៀនមានសិទ្ធិជ្រើសរៀនវិជ្ជាបានពីរផ្លូវ កំណត់វិជ្ជាពិសេសនេះទុកសម្រាប់ឲ្យអ្នករៀនជ្រើសរើសយកតាមសេចក្តីពេញចិត្ត ក្នុងវិជ្ជាទាំង ២ ផ្លូវនោះ ក្នុងមួយផ្លូវៗ ញែកចេញទៅជា វិជ្ជាសាមញ្ញ វិជ្ជាវិសាមញ្ញ ។ ការដែលចាត់ទុកដូច្នេះ ក៏ដើម្បីនឹងបើកឱកាសឲ្យអ្នករៀនដែលត្រូវការនឹងប្រកបអាជីវភាពក្នុងពេលដែលខ្លួនរៀនសម្រេចហើយ អាចនឹងធ្វើការបានមួយរំពេចភ្លាម ។ មេរៀនដែលញែកបង្រៀនជាពិសេសសម្រាប់អ្នកដែលមានបំណងនឹងចេញទៅធ្វើការរកស៊ី គឺយកជីវិតទៅប្តូរចំពោះការងារនោះ ។ គេបានចាត់ឲ្យមានទម្ងន់ទៅក្នុងផ្លូវហ្វឹកហាត់ការងារ នឹងហ្វឹកហាត់ពិសោធន៍វិទ្យាសាស្ត្រ ។

បរិមាណខាងមេរៀន ខាងផ្លូវសាមញ្ញនោះ បានចាត់ទុកចំពោះ អ្នករៀនដែលមានបំណងចង់ចូលរៀនបន្តវិជ្ជាជាន់ខ្ពស់ទៅទៀត ដូចមហាវិទ្យាល័យជាដើម,

ការដែលបង្រៀនក៏មានទម្ងន់ទៅខាងភាសាបរទេសច្រើនជាង. និងគណិតសាស្ត្រ ។

វិជ្ជាទាំង ២ ផ្នែកនេះ ក្នុងមួយសប្ដាហ៍កំណត់ពេលរៀនជាច្រើនម៉ោង ។ សាលារៀនមធ្យមសិក្សាដែលនៅតាមទីក្រុងធំៗក៏បានបង្រៀនតាមរបៀបមធ្យមសិក្សាតាមផ្លូវទី២នេះជាច្រើន; ក្រសួងសិក្សាធិការជាអ្នកចាត់របៀបបែបផែនដែលសម្រាប់បង្រៀនព្រមទាំងចាត់ពេលវេលាឲ្យបង្រៀនហើយដាក់កំណត់បង្គាប់យ៉ាងម៉ឺងម៉ាត់ ដើម្បីឲ្យបានសមរម្យឲ្យទៅជារបៀបតែមួយទូទៅក្នុងព្រះរាជអាណាចក្រ ។ បែបបង្រៀនក្នុងថ្នាក់មធ្យមនោះ ត្រូវតែបានទទួលការយល់ព្រមអំពីក្រសួងសិក្សាធិការជាតិជាមុនដាច់ ។ តាមការស្ថិតិក្នុង ព.ស. ២៤៧៨សាលារៀនមធ្យមសិក្សាក្នុងព្រះរាជអាណាចក្រជប៉ុនទាំងមូលមាន ៥៥៥ សាលា មានអ្នករៀន ៣៣០.៩២២ នាក់ក្នុងចំនួនសាលារៀនទាំងនោះ មានសាលារៀនឯកជន ១១៧ សាលា ក្រៅអំពីនោះ ជាសាលារៀនបែប "ប៉ាប់លិគស្គូល" ដែលពឹងផ្អែកទៅលើថវិកាខេត្តតាមទីក្រុងធំៗ មានអ្នករៀនស្ម័គ្រចូលសាលារៀនមធ្យមមានចំនួនច្រើនជាង សាលារៀននៅតាមជនបទ ។

ខាងក្រោយមហាសង្គ្រាមមក អ្នករៀនក្នុងសាលារៀនមធ្យមបានទៅចំនួនកាន់តែច្រើនឡើង, តែក្នុងរយៈ ២-៣ ឆ្នាំតមក ចំនួនអ្នករៀនក្នុងថ្នាក់មធ្យមក៏បានថយតិចចុះជាងឆ្នាំមុនៗ ដោយហេតុមកអំពីអ្នកដែលរៀនសម្រេចវិជ្ជាក្នុងថ្នាក់បឋមសិក្សាហើយ បាននាំគ្នាស្ម័គ្រចូលរៀនខាងវិជ្ជាជីវៈក្នុងសាលារៀនជាងជាច្រើន ។ បើនិយាយក្នុងវង្វង់ប្រវត្តិសាស្ត្រ ក៏នឹងឃើញថាសាលារៀនមធ្យមនេះជាជណ្ដើរកាំដំបូងដែលសម្រាប់ឲ្យអ្នករៀនឡើងដើរទៅកាន់ឧត្ដមសិក្សាតទៅ, ព្រោះដូច្នោះទើបបានកំណត់វេលា បង្រៀនភាសាជប៉ុន វណ្ណគតិរបស់ចិន ភាសាបរទេស គណិតសាស្ត្រនិងវិទ្យាសាស្ត្រទុកឲ្យច្រើនជាងវិជ្ជាប្រភេទដទៃ ។ ក្នុងពេលថ្មីៗនេះ ខាងផ្លូវការ បានបន្ថែមកាយបរិហារនឹងហ្វឹកហាត់ការងារបញ្ចូលទៅក្នុងបទរៀនមធ្យមសិក្សាផងទៀត ។ ហេតុនេះតាមសាលារៀនមធ្យម ទើបមានកេង... និងសាលាហ្វឹកហាត់ការងារ និវាសដ្ឋានកន្លែងសម្រាប់ឈប់សម្រាកក្នុងរដូវក្ដៅ និងទីកន្លែងសម្រាប់លំហើយអារម្មណ៍ដទៃៗ ដែលមានវត្ថុបំណងស្របគ្នា ។

## សាលារៀនមធ្យមស្រី

សាលារៀនមធ្យមស្រីដែលហៅ "ហៃស្គូល" នេះជាកន្លែងសិក្សាដែលមានសេចក្ដីបំណងនឹងបណ្ដុះបណ្ដាលវប្បធម៌ខាងការសិក្សានិងមុខងារដែលជាការចាំបាច់ដល់ស្ត្រី ប្រឹងព្យាយាមអប់រំស្រីក្រមុំជាតិជប៉ុនឲ្យយកចិត្តទុកដាក់ក្នុងធម្មចរិយារបស់ជាតិ និងគុណ-សម្បត្តិរបស់ស្ត្រី ។ បទរៀនក្នុងសាលារៀនមធ្យមស្ត្រីនេះ កំណត់តាំងពី ៣ ឆ្នាំដល់ ៥ ឆ្នាំ អ្នក

រៀនស្រីដែលនឹងចូលរៀនក្នុងសាលារៀនមធ្យមនេះបាន លុះណាតែបានរៀនសម្រេចវិជ្ជាតាមថ្នាក់សាលារៀនបឋមសិក្សាមកសព្វគ្រប់ហើយ មិនតិចជាង ៦ ឆ្នាំ ។ ចំណែកអ្នកដែលធ្លាប់រៀនក្នុងសាលារៀនបឋមថ្នាក់ខ្ពស់ ឬបឋមវិសាមញ្ញមកហើយចំនួន ២ ឆ្នាំ បូករួមពេលដែលបានរៀនក្នុងសាលារៀនបឋមសិក្សាមកហើយចំនួន ៨ ឆ្នាំនោះ រយៈវេលាដែលរៀនក្នុងសាលារៀនមធ្យមសិក្សាដែលកំណត់យ៉ាងយូរមិនហួសពី៥ឆ្នាំនោះ ឲ្យបន្ថយចុះនៅត្រឹមតែ ៣ ឆ្នាំ ។

សាលារៀនមធ្យមសិក្សាស្ត្រីនៅកន្លែងខ្លះ គេបានបញ្ចូលវិជ្ជារឿងមេផ្ទះទៅក្នុងបទរៀននោះផងទៀត ទាំងនេះក៏ដើម្បីនឹងបង្រៀនបណ្ដាអ្នករៀនស្ត្រីឲ្យទៅជាមេផ្ទះ និងទៅជាមាតាដ៏សំខាន់របស់ជាតិ ។

សាលារៀនមធ្យមសិក្សាស្ត្រីនៅកន្លែងខ្លះ ការបង្រៀនមានទម្ងន់ធ្ងន់ទៅខាងវិជ្ជាការផ្ទះសម្បែងតែម្យ៉ាង តែក៏មិនជាមានច្រើនសាលាទេ ។ សាលារៀនស្ត្រីដែលបង្រៀនវិជ្ជាមេផ្ទះតែម្យ៉ាងនេះ ភាសាជប៉ុនហៅថា "ជិតខាក្កូតូបូហ៉ាកខូ" ។ សាលារៀនស្ត្រីបែបនេះកំណត់ពេលរៀនតាំងពី២ឆ្នាំដល់៣ឆ្នាំ ជាកន្លែងសិក្សាជាន់ខ្ពស់សម្រាប់ស្ត្រីជាតិជប៉ុន ។

វិជ្ជាដែលបង្រៀនក្នុងសាលារៀនមធ្យមស្ត្រីមានបង្រៀនចរិយា. នាទីរបស់ពលរដ្ឋ ភាសាជប៉ុន ភាសាបរទេស ប្រវត្តិសាស្ត្រ ភូមិសាស្ត្រ គណិតសាស្ត្រ វិទ្យាសាស្ត្រ, ជាងគំនូរ វិជ្ជាមេផ្ទះ ដេរប៉ាក់ ដោតក្រង វិជ្ជាតន្ត្រី និងកាយបរិហារ ក្រៅអំពីនេះនៅមានបន្ថែមបទរៀនទៀតគឺ ហ្វឹកហាត់ថ្វីដៃឲ្យស្អាតជំនាញនឹងជំនាង ។ ក្រសួងសិក្សាធិការជាតិជាអ្នកដាក់កំណត់នូវវិជ្ជា និងការបង្រៀនទុកឲ្យហើយត្រួតត្រាដោយសព្វគ្រប់ រហូតដល់បែបបង្រៀនដែលប្រើបង្រៀនក្នុងសាលារៀនផងទៀត ។

កាលពី ២-៣ ឆ្នាំដែលកន្លងទៅហើយនេះសាលារៀនមធ្យមស្ត្រី ក្នុងប្រទេសជប៉ុនបានចំរើនឡើងជាច្រើនហើយ ជាស្ថានសិក្សាដ៏សំខាន់របស់ស្រីក្រមុំជាតិជប៉ុន ក្នុងប្រទេសជប៉ុនមានសាលាបែបនេះ ៩៧០ សាលា ដែលគេទុកថាជាមានតិចជាងសាលារៀនមធ្យមរបស់ប្រុស ឯអ្នករៀនដែលកំពុងរៀនមាន ៣៨៨.៩៣៥ នាក់ ។ ជាការអស្ចារ្យចំឡែកណាស់ដែលអ្នករៀនស្រីក្នុងសាលារៀនមធ្យម មានចំនួនទ្វេឡើងរាល់ៗឆ្នាំ ផ្សេងពីសាលារៀនមធ្យមខាងប្រុសៗ ។ រឿងនេះមកអំពីសាលារៀនវិសាមញ្ញ (គឺសាលារៀនខាងជាង ប៉ែកខាងស្រីមានចំនួនតិចជាងបុរស ហេតុនោះបានជាសាលារៀនមធ្យមស្ត្រីកើតទៅជាស្ថានសិក្សាយ៉ាងសំខាន់បំផុត សម្រាប់អប់រំ យុវនារីជាតិជប៉ុនឲ្យមានចំណេះវិជ្ជាខាងផ្លូវវឌ្ឍនធម៌ និងមុខងារដ៏សំខាន់របស់ស្រីដែលនឹងទៅជាមេផ្ទះ ឬជាមាតាដ៏ល្អរបស់ជាតិ"

សាលារៀនមធ្យមស្ត្រីមានរបៀបក្នុងការបង្រៀនដូចគ្នានឹងសាលារៀនមធ្យមរបស់បុរស ការបង្ហាត់ក៏

មានខមូនកូនទៅខាងផ្លូវវិទ្យាគារ ដើម្បីឲ្យស្ត្រីជប៉ុនទៀត ទៅជាមនុស្សមានសតិបញ្ញានិងការចេះដឹងពិតប្រាកដ ។ កាលពី ២-៣ ឆ្នាំ ដែលកន្លងមកហើយនេះ វត្ថុបំណងរបស់សាលាស្ត្រីមានការផ្លាស់ប្តូរទៅខ្លះ មកអំពីខាងផ្ទះការ ប្រកាន់ខាប់ថា វិជ្ជាដេរប៉ាក់ និងរបៀបកាន់គ្រួសារ ជាវិជ្ជាសំខាន់ ។ ការដែលឧបត្ថម្ភដាក់របៀបបែបរៀនថ្មីនេះ គឺដើម្បីជាការលើកស្ទួយវិទ្យាស្ថានរបស់អ្នករៀនឲ្យមានសមត្ថភាពធ្វើការរកស៊ីចិញ្ចឹមជីវិតបានក្នុងពេលខ្លួនរៀនសម្រេចវិជ្ជាហើយនោះ ។ ដោយចំពោះសាលារៀនមធ្យមស្ត្រីនេះបានព្យាយាមបង្រៀនខាងផ្ទះគេហ្វា និងខាងផ្លូវបដិបត្តិ, ក្រៅអំពីនេះមានបង្ហាត់វិជ្ជាពលសិក្សាឬកាយបរិហារបញ្ចូលទៅក្នុងមេរៀន ដើម្បីរក្សាសុខភាពនិងអនាម័យរបស់អ្នករៀន ទើបគេតាំងសាលារៀននិងឡប់សម្រាប់គ្រួសារ និងកន្លែងសម្រាកក្នុងរដូវក្តៅទុកសម្រាប់អ្នករៀនស្ត្រីផងទៀត ។

ម្យ៉ាងទៀត ក្នុងសាលារៀនមធ្យមសិក្សាស្ត្រីកន្លែងខ្លះ បានបញ្ចូលវិជ្ជាពិសេសផ្សេងៗ ដូចយ៉ាងការតាក់តែងរៀបផ្កាឈើ ការហាត់អក្សរផ្ចង់ ការហាត់កវិនិពន្ធ ពិធីលៀងទឹកតែ វិជ្ជាតន្ត្រីជប៉ុននិងសាកល របៀបកំរែបបជប៉ុនសម័យបូរាណ ក៏បញ្ចូលទៅក្នុងមេរៀនផងទៀតដែរ ។

ប្រែចាកសៀវភៅវិទ្យាសារ ភាសាថៃ

ដោយមហា ឃាស-ជាង



## ហេតុដូចម្តេចបានជាខាងខ្ញុំត្រឡប់ទៅជាសាវិកានៃព្រះពុទ្ធសាសនា?

រៀបរៀង ដោយនាងកញ្ញា ធុប-តេន-ជូ-ស្គី (Thup-Ten-Chò-Skyi) ហៅ គេត្ស-ស៊ុល (Getsul) ។

ពីថ្ងៃអាទិត្យ ទី៩ ឧសភា ១៩៥៥, នាងកញ្ញា ដឺឡាណូ (Delannoy) បានបួសជាសាមណេរី ក្នុងឱកាសពិធីបុណ្យមួយតាមគន្លងព្រះពុទ្ធសាសនា, ចំពោះព្រះភក្ត្រព្រះសង្ឃដែលជាអ្នកបំបួសនាងនេះនៅ គន្ធមាទវិហារ (Gandhamadan Vihara) ឯក្រុង ដាជេលិង (Darjeeling) ។ នាងបានទទួលនាមបញ្ញត្តិថា ធុប-តេន-ស្គី (គេត្ស-ស៊ុល) ប្រែជាភាសាបាលី

ជាមុនីសាសនៈ ធម្មានន្ទា (សាមណេរី), សព្វថ្ងៃនាងគង់នៅវត្តពោធិគយា ។

ជីវប្រវត្តិចំពោះបុគ្គលដែលមានន័យគ្រប់គ្រាន់ លុះត្រាតែជីវប្រវត្តិនោះមានធម៌ជាមូលដ្ឋាន ។ នាងខ្ញុំសូមឲ្យការពិសោធន៍របស់នាងខ្ញុំជាផ្លូវមួយ ក្នុងការស្វះស្វែងរកសច្ចធម៌ ។

"នាងខ្ញុំជាសាស្ត្រាចារ្យនៃទស្សនវិជ្ជានិងអក្សរសាស្ត្រ ។ ពិតមែនតែនាងខ្ញុំជាបុត្រីអ្នកក្រុងនិងអ្នកកវី នាងខ្ញុំបានស្គាល់ប្រទេសឥណ្ឌៀ តាមនាមលោកគន្ធីនិងលោកតាគរ ដោយនាងខ្ញុំបានអានសេចក្តីនៃសៀវភៅអ្នកនិពន្ធឥណ្ឌៀរបស់លោកសាស្ត្រាចារ្យលេវីន្ទ (តែបើតាមពិត កិច្ចការនៃវិទ្យាសាស្ត្រទាំងនេះមិនមែននាំឲ្យខូចនូវតម្លៃខាងសាសនាទេ) ។ នៅ គ.ស. ១៩៤៧, នាងខ្ញុំបានទៅទស្សនា "កណ្ឌានិកេតន៍ គិលមេត៍" ។ តែមុននឹងនាងខ្ញុំពណ៌នានូវព្រឹត្តិការណ៍ដែលនាំឲ្យធម្មជាតិនៃចំណេះរបស់ខ្ញុំប្រែប្រួលទៅបាន នាងខ្ញុំសូមអភ័យទោសជាមុន សូមជំរាបជូនអតីតប្រវត្តិរបស់នាងខ្ញុំសិន ។

ដំបូង, នាងខ្ញុំកាន់សាសនាកាតូលិក, ដោយនាងខ្ញុំមានចេតនាជាយ៉ាងជ្រាលជ្រៅខាងជីវភាពអាទិទេព, មិនមែនដោយចិត្តវិប្បយុត្តជាតំណតមកពីទំនៀមទម្លាប់គ្រួសារនោះទេ ។ នាងខ្ញុំមានឯកសិទ្ធិបានចូលទៅសិក្សាខាងគណៈគ្រិស្តសាសនាហៅថាថូមីស្ត (ប្រែថា លទ្ធិសាំង–ថូម៉ាស់–អាគាំង «Saint-Thomas Aquin» ជនកបុរសខាងលទ្ធិអាទិទេព និងទស្សនវិជ្ជាមួយយ៉ាង ខាងគ្រិស្តសាសនា) រស់នៅដោយពិចារណានូវធម៌របស់ពួកដូមីនីកាំង (ជាធម៌របស់បណ្ឌិតសាំងដូមីនិក ខាងគ្រិស្តសាសនា) នៅក្នុងមហាវិទ្យាល័យ "ឌុយសុលស្វារ" (Université du «Saulchoir») ។ គឺនៅក្នុងទីនោះឯងដែលនាងខ្ញុំបានរៀនរកប្រែគំនិតនាងខ្ញុំជាថ្មី ។ ពួកអាទិទេវលទ្ធិបណ្ឌិតសំខាន់ៗ ខាងលទ្ធិគ្រិស្តសាសនាជាអ្នកមគ្គុទ្ទេសក៍របស់នាងខ្ញុំ ដូចជាបណ្ឌិតសាំងអូគុស្តាំង (Saint Augustin) បណ្ឌិតដឺនិស (le Pseudo Denys) បណ្ឌិតសាំង-ប៊ែរណារដ៍ Saint Bernard) បណ្ឌិតតូលែរ (Tauler) បណ្ឌិតសង់ដឺឡាក្រូា (Jean de la Croix) ព្រមទាំងសៀវភៅអាទិទេវលទ្ធិផ្សេងៗដែលមានទំព័ត្ភាពគួរជាទីនិយមខាងសាលារៀន ហើយបើអ្នកណាអាចយល់បានមានវិចារណញ្ញាណគួរបញ្ចូលទៅក្នុងគម្ពីរនាមថា: ជ្ញានយោគៈ (Jnàna yoga) ។ នាងខ្ញុំមានជីវភាពប្រកបដោយវិបស្សនាធុរៈព្រមទាំងវាទសិល្បៈ ព្រោះថាវាទសិល្បៈខាងគ្រិស្តសាសនិកជនមិនមែនមានសភាពថោកថយជាងសមាធិនៃសាសនាឥណ្ឌៀទេ ។ វាទសិល្បៈនិងសមាធិទាំងពីរបែបដែលអាចផ្គង់ចិត្ត ឲ្យចូលទៅស្និតក្នុងអារម្មណ៍ប្រកបដោយប្រាជ្ញា, មានន័យគួរឲ្យជ្រះថ្លា, តែងមានគាថាបញ្ជាក់អំពីទស្សនវិជ្ជា, តែបើអ្នកណាមួយឃើញចំពោះវាទសិល្បៈជាប្រហែលនឹងធម៌ "ភក្តិ" «bhakti» គឺយល់ខុស ។ នាងខ្ញុំមានចិត្តស្ងាពេញ

លក្ខណៈ អាចចូលទៅក្រោយយកអត្ថរសចំពោះការលំបាកខាងវិធីបដិបត្តិសាសនា ពិតមែនតែមានសេចក្តីតំរាមកំហែង (និវរណធម៌និងឧបក្កិលេស) ដែលផុសផុលពីក្នុងខន្ធសន្តានរបស់ខ្ញុំ ៗ ដំបូងមានន័យជាអកុសលកម្មៗ នេះដូចជាបំណងចង់បំផ្លាញខ្ញុំ: តែមិនមានបំណងអាក្រក់សោះឡើយ នាងខ្ញុំបានយកប្រាជ្ញាអាចចុះបំភ្លឺឲ្យឃើញច្បាស់នូវអកុសលកម្មនោះ ៗ នាងខ្ញុំអាចពោលបានដូចលោកសង់ប៉ូល (Saint-Paul)បានពណ៌នាថា: “ខ្ញុំប្រព្រឹត្តធម៌ជាអកុសលដែលខ្ញុំស្អប់ពន់ពេក ហើយខ្ញុំមិនបានបំពេញធម៌ជាកុសលទៅតាមបំណងរបស់ខ្ញុំសោះឡើយ ៗ ឱខ្ញុំជាបុគ្គលអភ័ព្វ! តើអ្នកណាអាចជួយខ្ញុំឲ្យផុតចាកពីរូបប្រកបដោយមរណៈនេះបាន?” ៗ ការសូមខមាទោសសូត្រធម៌ប្រតិបត្តិធម៌ មិនអាចធ្វើខ្ញុំឲ្យរួចពីចំណងខន្ធនេះបាន! ឱគួរឲ្យអាណោចអធ័មពន់ពេកចំពោះរូបនាងខ្ញុំ!

តាមផែនការលទ្ធិ,មានវត្ថុជាច្រើនដូចមុខកាំបិតផុសផុលអណ្តែតឡើងពីក្នុងសន្តានចិត្តខ្ញុំ, តែមិនមែនមកពីលទ្ធិនេះឬលទ្ធិនោះទេ, គឺផុសផុលមកពលដាលពីលើស្រទាប់ចិន្តាក្រោក់ ដែលខ្ញុំធ្លាប់គិតធ្លាប់សិក្សាពីមុនមក ៗ គ្រិស្តសាសនា, ដូចជាពុទ្ធសាសនា គឺជាសីលធម៌ ឬទស្សនវិជ្ជា បើមិនមែនសីលធម៌ក៏គង់ទៅជាទស្សនវិជ្ជាសាសនានីមួយៗតាមប្រពៃណីនិយមបញ្ជាក់នូវប្រាជ្ញាគ្មានសភាពប្រែប្រួលលាយប្រឡំទៅនឹងសភាពគគរល្អក់នៃលទ្ធិជាច្រើនប្រមូលបញ្ចូលចំរុះគ្នា ៗ ចិត្តសន្តោសពិតប្រាកដ មិនមែនជាផ្លូវតាំងអស់នាំទៅទីក្រុងរ៉ូមទេ ហើយថាយប់ពីថ្ងៃនោះសោះឡើយ, តែត្រូវសំរិតសំរាំងមនោធម៌ឲ្យចេញចាកពីនិវរណធម៌ជាគ្រឿងស្មោគគ្រោក ៗ ឯកភាពដែលស្ថិតនៅក្នុងខន្ធសន្តានខ្ញុំ រីតែតែបំភ្លឺខ្ញុំឲ្យយល់នូវធម៌បានដោយឧបាយនៃប្រាជ្ញាដ៏ប្រពៃ នឹងរកតែធ្វើខ្ញុំឲ្យគោរពនូវឯកភាពដែលស្ថិតនៅក្នុងមនោធម៌អ្នកដទៃ លុះត្រាតែមនោធម៌ទាំងពីរនេះបានទៅជួបប្រទះនឹងសច្ចធម៌ ៗ គ្រិស្តសាសនាមានសភាពដូចជាស្ថិតនៅក្នុងមូលដ្ឋាន ដ៏ពិតប្រាកដក្នុងប្រវត្តិសាស្ត្រ ហើយមានចិត្តទោរទន់ទៅកាន់មនុស្សជាតិដោយជឿជាក់ថា “នៅក្នុងរូបនីមួយៗមាន” មនុស្ស-អាទិទេព (l'homme Dieu) គ្រប់ៗគ្នា ៗ សភាពដ៏ឧត្តុង្គឧត្តមនៃការណ៍ដែលមានក្នុងលទ្ធិប្រកបដោយនិទ្ទេសភារៈនៃអត្ថបទគាថា សាសនានាំមនុស្សទៅកាន់លទ្ធិសម្ភារនិយម, បើយើងពិនិត្យនូវដំណើរនៃការសិក្សាវិជ្ជាទាំងនោះឲ្យហ្មត់ចត់ ៗ ខ្ញុំមានសេចក្តីព្រួយបារម្ភជាខ្លាំងក្នុងពេលនោះ រួចខ្ញុំបានអានអត្ថបទនៃលោកសង់ប៉ូល (Saint-Paul) ថាបើព្រះគ្រិស្តមិនបានរស់ឡើងវិញម្តងទៀតទេ ជំនឿរបស់យើងជាការឥតប្រយោជន៍ ៗ ការសិក្សាខាងគ្រិស្តសាសនាដែលយកការពិចារណាក្នុងខន្ធជាគោលការណ៍ ពិតមែនតែធម៌នោះស្ថិតនៅក្នុងព្រះរូបព្រះអាទិទេព ទៅជាមានលក្ខណៈផ្ទុយនឹងសភាពបរិសុទ្ធ, ឧត្តមភាពទៅវិញ ៗ គ្រិស្តសាសនានេះអួតថាចង់ជួយមនុស្ស

ជាតិដោយលេសថា. ខាងពួកនេះគេផ្ទុយនូវសេចក្ដីស្នេហាចំពោះព្រះអាទិទេពដែលមិនមែននាំខ្ញុំទៅកាន់ព្រះអាទិទេពដែលខ្ញុំមិនស្គាល់ទេ, ព្រះអាទិទេពដែលមានស្ថិតនៅលើសិលាចារឹកក្រិក, តែនាំខ្ញុំទៅកាន់លទ្ធិអាត្មន៍ដែលខ្ញុំពុំទាន់ស្គាល់ដែរ គឺៈ តថាគតដែលមានន័យថា សព្វញ្ញាតញ្ញាណឬសព្វញ្ញុពុទ្ធ (Absolu), ពិចារណាក្រៅពីវត្ថុដែលគិតឃើញ ក្រៅពីរឿងដែលគេយល់បាន ក្រៅពីប្រភេទនិងហេតុព្រមទាំងការវែកញែកពិនិត្យខាងចិត្តវិទ្យានិងអនុលោមវិទ្យា ដើម្បីនឹងបានយកពីក្នុងខន្ធសន្តានរបស់មនុស្សទូទៅកិលេស ហើយធ្វើមនុស្សឲ្យរឹងស្ងួតហួតហែងចាកចេញពី "មនុស្សប្រក្រតិ" ។ ដូនណាបញ្ហាខាងគ្រិស្តសាសនាទំនើបធ្វើឲ្យនាងខ្ញុំអន់ថយនូវសេចក្ដីជ្រួលច្របល់ក្នុងចិត្តនាងខ្ញុំ ។ បើនៅក្នុងសតវត្សរ៍ទី១៣ ប្រហែលជាការជ្រួលច្របល់ក្នុងចិត្តខ្ញុំមានសភាពអន់ថយកំឡាំងពន់ប្រមាណ ។

ខ្ញុំមានបំណងទៅកាន់បញ្ញាវិមុត្តិ ផ្ទុយពីអាទិទេពលទ្ធិ-ឧត្តមភាព (អាទិទេពលទ្ធិ=គ្រិស្តសាសនា-ឧត្តមភាព=សក្តិសិទ្ធ (Saktisme) នឹងតន្ត្រលទ្ធិ (tantrisme) ព្រមទាំងទម្រង់យោគៈផ្សេងៗ, រឿងលែងតែជាឧបញ្ញាណប៉ុណ្ណោះ) ។ គ្រិស្តសាសនាមិនអាចបំភ្លឺខ្ញុំឲ្យវែកញែកគំនិតទាំងនោះឲ្យយល់បានច្បាស់លាស់ ។

(មានត)

x x

x

និទានខ្លីៗ

## ១- រឿងមនុស្សខ្វាក់កាន់ចង្កៀង

ក្នុងវេលារាត្រីមួយដ៏ងងឹតសូន្យសុង, បុរសខ្វាក់ម្នាក់កាន់ចង្កៀងនៅដៃ, លីក្អមមួយតូចលើស្មាដើរទៅកាន់រ៉ៃ ១ ។ មានបុរសម្នាក់ទៀត ឃើញអន្ធបុរសនោះហើយ និយាយថា "នែបុរសល្ងង់, អ្នកឯងដើរយប់ ដូចជាដើរថ្ងៃ, ដើរថ្ងៃ ដូចជាដើរយប់ទេ, ការប្រើចង្កៀងនេះ គឺមានប្រយោជន៍អ្វីដល់អ្នកឯង?"

បុរសខ្វាក់ ឮហើយក៏សើច រួចនិយាយថា "ខ្ញុំកាន់ចង្កៀងនេះ មិនមែនមានប្រយោជន៍អ្វីដល់ខ្ញុំទេ, គឺសម្រាប់អ្នកទេតើ ព្រោះខ្ញុំនឹកថា បើអ្នកដើរមកក្នុងទីងងឹត អ្នកមិនឃើញខ្ញុំ មុខជាប៉ះនឹងខ្ញុំ ហើយនាំឲ្យបែកក្អមរបស់ខ្ញុំ ។ ព្រោះហេតុនោះ បានជាខ្ញុំកាន់ចង្កៀងនេះមក ។

### គតិទិពន្ធ៍

| | | |
|---|---|---|
| បុរសខ្វាក់ | អាចទៀត | រកឧបាយ |
| ការពារ | អន្តរាយ | កុំឲ្យមាន |
| ចាត់ជា | អ្នកមាន | ប្រាជ្ញាញាណ |
| សន្តាន | វៃឆ្លាត | គប្បីជ្រាប ។ |

x

x x

## ២. មហាសេដ្ឋីនិងបងកំសត់

កាលមួយ បុរសមហាកំសត់ម្នាក់ បានចូលទៅរកលោកមហាសេដ្ឋីម្នាក់, និយាយថា "បពិត្រលោកមហាសេដ្ឋី, យើងទាំងពីរនាក់ ជាកា-ទិកម្មិកបុគ្គល (អាជាប)? ព្រោះហេតុនោះ យើងត្រូវជាបងប្អូននឹងគ្នា" ។ ចំណែកខាងលោក ជាអ្នកមានទ្រព្យច្រើន, ខ្ញុំជាបុគ្គលទាល់ក្រណាស់ ។ សូមលោកមេត្តាឲ្យនូវចំណែកដែលបងត្រូវបាន ដល់ខ្ញុំ ។ ឮពាក្យនោះហើយ មហាសេដ្ឋីក៏ឲ្យប្រាក់១រៀលដល់បុរសកំសត់នោះ ។ គ្រានោះ ទុគ្គតបុរសនិយាយថា "នុ! លោកមហាសេដ្ឋី, ព្រោះហេតុអ្វីបានជាលោកមិនឲ្យនូវចំណែកដែលបងត្រូវបាន ដល់ខ្ញុំ? ។ សេដ្ឋីពោលថា "ម្នាលប្រិយមិត្រ ! បើអ្នកសន្តោសតាមមានតាមបានទៅចុះ បើខ្ញុំចេះតែឲ្យប្រាក់មួយរៀលៗ ដល់បងប្អូនទាំងអស់ ដែលទាល់ក្រ នោះនឹងគ្មានប្រយោជន៍អ្វី សូម្បីតិចបន្តួចដល់ខ្ញុំវិញសោះ" ។

### គតិអ្នកនិពន្ធ

កំណាញ់ ជាធម៌ ដ៏លាមក
ប្រាជ្ញកុំ យកទុក ក្នុងសន្តាន
បើមាន ទ្រព្យច្រើន គួរឲ្យទាន
ដើម្បី ធ្វើប្រាណ បានសុខហើយ!

x x

x

## ៣- រឿងយាចកាក

កាលកន្លងទៅហើយ មានយាចក (អ្នកសូម) ម្នាក់ គិតថា បើប្រសិនណាអញក្លែងខ្លួនធ្វើជាមនុស្សគ មុខជានឹងបានលុយកាក់ប្រាក់កាសច្រើនពុំខាន, លុះគិតដូច្នេះហើយ មួគបុរសនោះ ក៏ឲ្យគេសរសេរពាក្យនៅលើផ្ទាំងក្តារមួយថា "ម្ញុំគោ (គ)" ហើយព្យួរនៅកដើរទៅឈរនៅក្បែរផ្លូវមួយ ។

មានយាចកម្នាក់ទៀតជាបច្ចាមិត្រ (សត្រូវ) របស់បុរសនោះគិតថា "អញនឹងញុំាងការកុហករបស់បុរសនេះឲ្យប្រាកដដល់អ្នកផងទាំងពួង" ហើយក៏ទៅអង្គុយក្នុងទីជិតបុរសគនោះ ។ កាលណា មានជនចិត្តសប្បុរសដើរចូលទៅជិត ដើម្បីនឹងឲ្យប្រាក់មួយកាក់-មួយសេនដល់បុរសដែលធ្វើជាគនោះ, កាលនោះ បើជននោះក៏ស្រែកថា "បពិត្រមហាសយៈ, សូមលោកកុំឲ្យអ្វីដល់គានេះ ព្រោះវាជាមនុស្សកុហកទេ មិនមែនគទេ ។ គ្រានោះ កុហកបុរសនោះ ក៏ខឹងប្រទៀតលោតត្តោរក្រមាល់ឡើង ហើយ ពោលថា "កាលកាលវេលា ខ្ញុំជាមនុស្សគ, ឥឡូវនេះក៏នៅតែគដដែល" ។ សម័យនោះជនសប្បុរសនោះ ក៏និយាយថា "មិនដែលមានទេ មនុស្សគណាដែលចេះនិយាយចរចាយ៉ាងនេះទេ" រួចហើយក៏ដើរចេញពីទីនោះទៅ ។

### គតិនិពន្ធការ

ពោលពាក្យ កុហក ឆប្រវញ្ចន៍
ចង់ឲ្យ ចំណេញ បានពេញចិត្ត
នោះឯង ជាធម៌ នៃពាលពិត
ព្រោះជន បណ្ឌិត តែងតិះដៀល ។

## ៤-) រឿងទន្សាយសម្លាប់រាជសីហ៍

ថ្ងៃមួយ ស្តេចម្រឹគ ត្រូវសេចក្តីស្រេកឃ្លានគ្រប សង្កត់ក៏ខឹងប្រឡោត ហើយនិយាយទៅកាន់ទន្សាយថា "ម្តេច ក៏អ្នកឯងក្រមកម្ល៉េះ?"; ទន្សាយប្រាប់ថា "នេះ មិនមែនជាកំហុសរបស់ខ្ញុំទេ" ។ ពេលដែលខ្ញុំកំពុង ដើរទៅតាមចន្លោះផ្លូវ ស្រាប់តែមានសីហៈមួយចេញ មកកំហែងខ្ញុំឲ្យត្រឡប់ទៅវិញ ។ បើលោកមិនជឿ សូមអញ្ជើញទៅមើលចុះ, ទាំងខ្លួនខ្ញុំ ក៏វាមិនទាន់ដោះ លែងឲ្យរួចទោសទេ គឺនៅក្នុងការព្យួរទោសនៅ ឡើយ ។

រាជសីហ៍ខឹងខ្លាំងណាស់ ក៏ស្ទុះទៅយ៉ាងលឿន ហើយនិយាយថា "អ្នកណា ចង់ប្រទូសរ៉ាយនឹងយើង ចូរអ្នកឯងបង្ហាញខ្ញុំ" ។ គ្រានោះទន្សាយក៏នាំសីហៈ នោះទៅកាន់មាត់អណ្តូងមួយដ៏ជ្រៅ ហើយនិយាយថា "បពិត្រចៅហ្វាយ សូមលោកមើលក្នុងចន្លោះអណ្តូង នេះ មានរូបសីហៈជាបច្ចាមិត្រនៅក្នុងទីនោះឯង" ។ គ្រានោះ រាជសីហ៍ក៏គំរាមស្រែកយ៉ាងខ្លាំង ហើយស្ទុះ ប្រោលចូលទៅភ្លាត់ស្នៀតធ្លាក់ក្នុងអណ្តូង ស្លាប់ប្រាណ ខានរស់ទៅហោង ។

### គតិនិពន្ធ៍

រាជសីហ៍ អំណាច មហស្ចារ្យ
តែគ្មាន ប្រាជ្ញា រកឧបាយ
ក្រេវក្រោធ លុះត្រា អន្តរាយ
ព្រោះតែ ទន្សាយ វាបញ្ឆោត ។

## ៥) ផលអាក្រក់នៃអកាលគោចរ

ក្នុងសម័យថ្ងៃមួយ ព្រះចៅពារាណសី បានយាង ទៅកាន់បច្ចន្តគ្រាម, ដើម្បីបង្ក្រាបពួកចោរ ។ ដោយ ទ្រង់យាងទៅក្នុងកាលមិនគួរ ទ្រង់បានសំចតកងទ័ព នៅក្នុងឧទ្យានមួយ ។ គ្រានោះឯងមានសត្វមៀមមួយ ហើរចូលទៅពួននៅក្នុងគុម្ពឫស្សីមួយ ។ ក្អែកទាំងឡាយ បានឃើញមៀមនោះហើយ ក៏ហើរមកចាំចឹក-ខាំមៀម ក្នុងពេលដែលវាចេញពីគុម្ពឫស្សីទៅ ។

(មានត)

X X X

## ប្រវត្តិក្មេងកំព្រា (ត)

### ហេតុកើតឡើងនៅលើកោះ

សំណាងនៅជាសុខក្នុងគូហានោះ អ្នកមិនដែល ចេញមកលេងខាងក្រៅសោះ ព្រោះខ្លាចជួបប្រទះលើ គ្រោះកាច, រាល់ពេលអ្នកតែងនឹកមិនភ្លេចទេក្រៅរបស់ ធន-សារឿន អ្នកចេះតែស្មានហើយស្មានទៀតថា "ប្រហែលជាសារឿនគេមានគូស្រករទៅហើយមើល ទៅ" ណាមួយអ្នកនឹកអាល័យមិនភ្លេចមកលោកដង្ហើ ប្រសើរនឹងនារីដែលទុកដូចជាឪពុកនិងប្អូនរបស់អ្នក ណាមួយនឹកមកលោកគ្រូរបស់អ្នកផង ពុំដឹងជាអ្នក មានគុណទាំងនោះសោកស្តាយស្វែងរកអ្នករបៀបណា ទេ; ណាមួយអ្នកចង់ត្រឡប់មកកាន់រាជធានីភ្នំពេញ វិញផង តែអ្នកពុំដឹងជាខំរកដោយមធ្យោបាយ

បែបណាមួយ  អ្នកសែនតុះតុញគំនិតឥតឧបមាចំណែក វិស្សមកាលក៏ជិតផុតហើយ  បំណាងនៃការសិក្សារបស់អ្នកក៏នៅតែមានដដែល  អ្នកនៅជាសុខក្នុងគុហា តែមនោរបស់អ្នកជាទុក្ខគ្រប់ទិវា ៗ  សំណាងជឿច្បាស់ថា  ការប្រតិបត្តិតាមគន្លងអ្នកពុទ្ធជន  គង់នឹងបានជួបសុភមង្គលនៅថ្ងៃណាមួយ;  សព្វថ្ងៃនេះយើងដឹងបានដែរថាអ្វីជាទីពឹងរបស់សំណាង?  មានតែព្រះរតនត្រ័យប៉ុណ្ណោះទេដែលអ្នកត្រូវទីពឹង ៗ  រាល់ពេលវេលាដែលអ្នកត្រូវនមស្សការព្រះពុទ្ធអង្គធំមួយនោះ  អ្នកតែងផ្គងចិត្តឲ្យនឹកចំពោះទៅលើគុណនៃព្រះត្រៃរតន៍  បានបំបួងសួងជានិច្ច  ក្រែងលោមានភ័ព្វនឹងបានចួងផុតពីកោះនេះ ៗ ការបួងសួងនេះពិតមែនតែធ្វើសំណាងឲ្យរស់សង្ឃឹម  គង់អ្នកនៅនឹកស្មានថាមានថ្ងៃណាមួយ  នឹងបានទៅជួបជុំនឹងត្រកូលរបស់អ្នកវិញ ៗ

## ទ្វារមួយប្លែកនៅក្នុងគុហា

ថ្ងៃនេះសំណាងបានយកសាដកសស្អាតមួយមកជូតសំអាតព្រះពុទ្ធរូបធំ  ដែលប្រតិស្ឋាននៅចំកណ្ដាលគុហា,  ដែលអ្នកកំពុងតែជូតសំអាត  ចិត្តរបស់អ្នកក៏ពុងតែនឹកដល់គុណព្រះត្រៃរតន៍  លុះអ្នកជូតមកដល់ព្រះភ័ក្ត្រព្រះបដិមាករ  អ្នកបានពិនិត្យព្រះភ័ក្ត្រព្រះអង្គហាក់ដូចជាញញឹមប្រុងនឹងប្រាប់ដំណឹងអ្វីមួយដល់អ្នក, ការរីករាយសប្បាយក្នុងចិត្តអ្នក  ហាក់ដូចជាបានជួបជុំគ្រួសារក្នុងពេលនេះ  អ្នកខំសំអាតដោយផ្ចិតផ្ចង់តទៅទៀត ការជូតនេះបានកើតឡើងជាពិសារ ដោយកម្លាំងបីតិរបស់អ្នក ៗ  ពេលដែលសំណាងកំពុងតែបោសអង្គុលបល្ល័ង្កខាងក្រោយ  អ្នកពុំបាននឹកក្នកថា នៅទីនេះជាទ្វារមួយទេ  មិនយូរប៉ុន្មាន  ទីបល្ល័ង្កក្រោយដែលស្អាតស្មើជេងនោះក្លាយទៅជាទ្វារមួយភ្លាមមួយរំពេច  នាំឲ្យអ្នកភ្ញាក់ខ្លួនព្រើតក្នុងពេលនោះ ៗ សំណាងនឹកឆ្ងល់ណាស់  ព្រោះថាអ្នកមកនៅទីនេះអស់ពេលយូរណាស់មកហើយ  ម្ដេចក៏ពុំបានដឹងថាកន្លែងនេះជាទ្វារ  ហើយមួយទៀត  ព្រះពុទ្ធរូបអង្គធំនោះសោត  ក៏អ្នកតែងតែជូតសំអាតគ្រប់តែថ្ងៃឧបោសថដែរ តែម្ដេចក៏មិនជួបប្រទះនូវទ្វារបែបនេះ ៗ

សំណាងបានចូលទៅតាមទ្វារនោះហើយ  ក៏ដើរចុះទៅតាមជណ្ដើរដែលបត់បែនជាច្រើនកន្លែង  ក្នុងរូងដ៏ប្លែកថ្មីក្រោយនេះ  ក៏គង់មានពន្លឺធម្មតាដូចជាគុហាខាងលើដែរ  អ្នកខំដើរចុះទៅដោយពុំទាន់មានឃើញអ្វីដែលនាំឲ្យប្លែកសោះ  គ្រាន់តែជាសភាពយ៉ាងស្ងប់ក្រៃលែង; បើអ្នកត្រឡប់មើលមកក្រោយវិញ  ពុំឃើញមានមាត់ទ្វារនិងជណ្ដើរដែលអ្នកចុះរួចមកហើយទេ  ឃើញតែជណ្ដើរដែលត្រូវចុះតទៅទៀត, ផ្លូវចុះនោះសោតក៏ពុំមែនសុទ្ធតែចុះទាំងអស់ហើយត្រង់នោះក៏ទេដែរ  គឺថាជួនកាលបត់បែនពីឆ្វេងទៅស្ដាំពីស្ដាំមកឆ្វេង  ជួនមានសភាពដូចជាឡើង  ជួនចុះ;  ការដើរក្នុងផ្លូវស្ងាត់នេះមានចំនួនប្រហែលជា ២០ នាទីប៉ុណ្ណោះ  ក៏ជួបប្រទះលើទីវាលស្រឡះមួយ  ដោយមានទីក្ដុកបដោយថ្មកែវ

សុទ្ធ នៅកណ្ដាលទីវាលនោះមានប្រាសាទបូរាណតូចមួយ ដែលមានស្រះបួនព័ទ្ធជុំវិញ ហើយមានផ្លូវចូលជាបួនទិស ស្រះទាំងបួននោះមានទឹកថ្លាក្រៃលែង គេអាចសំឡឹងមើលឃើញដល់បាតស្រះ, សេចក្ដីអស្ចារ្យក្នុងស្រះនោះមានសភាពដូចតទៅនេះ ស្រះទី ១ គេឃើញមានសុទ្ធតែវត្ថុសម័យបូរាណ ដែលជាព្រះរាជ-ទ្រព្យនៃមហាក្សត្រសម័យមុន ជាមាសសុទ្ធទាំងអស់, ស្រះទី ២ ក៏មានវត្ថុដូចស្រះទី ១ ដែរ តែជាវិការនៃប្រាក់, ស្រះទី ៣ ជាគ្រឿងនៃត្បូងពេជ្រ ក៏មានរស្មីចាំងចេញយ៉ាងអស្ចារ្យ ស្រះទី ៤ ជាគ្រឿងត្បូងចម្រុះគ្រប់ព័ណ៌ មច្ឆាជាតិហែលហែបពាសពេញដែលមានព័ណ៌ផ្សេងគ្នាដែរ ។

សំណាង អ្នកជាប់ចិត្តលើស្រះទាំងនេះយ៉ាងក្រៃលែង អ្នកបានដើរមើលដោយចិត្តរីករាយជាទីបំផុត, ត្រង់នេះគួរកើតជាបញ្ហាមួយថា ចុះសំណាងតែម្នាក់ឯងគត់ មកជួបប្រទះលើវត្ថុអស្ចារ្យបែបនេះ ហើយគ្មានជនណាម្នាក់នឹងពិភាក្សាសួរសោះ តើចិត្តអ្នកបែបណាទៅវិញ ? យើងឆ្លើយថា សំណាងពិតមែនតែជួបលើវត្ថុដែលគួរឲ្យអ្នកពិចពិលរមិលមើល នឹងជាវត្ថុគួរបំពេញដល់តណ្ហារបស់លោកជន ចំណែកចិត្តរបស់អ្នកបានប្រព្រឹត្តទៅបែបនេះគឺ អ្នកមានចិត្តរន្ធត់ជានិច្ចព្រោះខ្លាចមានសេចក្ដីអន្តរាយដល់ខ្លួន, សំណាងពុំមានចិត្តជាប់ជំពាក់លើគ្រឿងវត្ថុទាំងនោះឡើយ សូម្បីការតាំងចិត្តថា អញនឹងយកវត្ថុទាំងនេះ ដើម្បីធ្វើខ្លួនឲ្យទៅជាមហាសេដ្ឋីមួយរូបក៏ឯកម្ដរដ្ឋក៏គ្មានទើតក្នុងដល់ អ្នកគ្រាន់តែសប្បាយរីករាយលើវត្ថុប្លែកអស្ចារ្យប៉ុណ្ណោះ, កាលបើអ្នកពិនិត្យមើលស្រះទាំងបួននេះរួចហើយ អ្នកបានដើរចូលតាមទ្វារខាងមុខ សំដៅទៅប្រាសាទតូចនោះ,មួងនេះគួរឲ្យអ្នកភ័យតក់ស្លុតយ៉ាងខ្លាំងព្រោះពុំសូវសំឡេងមនុស្សនិយាយគ្នាអ្វីនៅទីនោះ តែមើលរូបមនុស្សពុំឃើញឡើយ មានសុទ្ធតែព្រះពុទ្ធរូបថ្មកែវនឹងខ្ទឹមច័ន្ទ នៅខាងមុខព្រះពុទ្ធរូបមានផ្កាដែលទំនងដូចជាមនុស្សទើបនឹងបេះយកមកថ្មីៗ នឹងក្លិនធូបកំពុងតែបង្ហុយក្លិនយ៉ាងក្រអូបឈ្ងុយឈ្ងប់, អ្នកចូលមកដល់ទីនេះត្រូវអង្គុយនមស្ការតាម ទំនងអ្នកពុទ្ធជនរួចក៏ដើរចូលទៅទីខាងមុខទៀត នៅខាងក្រោយទីដម្កល់ព្រះពុទ្ធរូបនេះ គេបានឃើញផ្ទាំងថ្មកែវមួយ ទំហំប្រហែលជាមួយម៉ែត្របួនជ្រុង មានជើងធ្វើពីមាសសុទ្ធសម្រាប់ទ្រផ្ទាំងថ្មកែវនោះ អ្នកមានសេចក្ដីសង្ស័យយ៉ាងក្រៃលែង ដោយឃើញផ្ទាំងថ្មកែវភ្លឺថ្លាដូចជាកញ្ចក់អាចនឹងឆ្លុះមុខបាន អ្នកបានយកដៃទៅស្ទាបអង្អែលក៏ឃើញសភាពរលីងដូចផ្ទៃកញ្ចក់សុទ្ធ ។

ពេលដែលអ្នកកំពុងតែពិនិត្យមើលដូចនេះ ក៏ស្រាប់តែលេចមុខនារីម្នាក់ ដែលអ្នកធ្លាប់ស្គាល់យ៉ាងជាក់ស្ដែងនៅក្នុងផ្ទាំងនៃថ្មកែវនោះ គឺភក្ត្រដ៏ប្រិមប្រិយនៃនារីធនសារឿន ភក្ត្រនៃនារីនេះបានញញឹមមករកអ្នក ថែមទាំងមានមាត់មួបៗ ហាក់ដូចជានិយាយរកអ្នកៗក៏ញញឹមនិយាយរកវិញ ដោយពាក្យថា សារឿនអូន

បងមានជីវិតនៅឡើយទេ និមិត្តតែចប់ពាក្យមួយឃ្លានេះ ក្បាលក្រពើដ៏ធំនេះក៏រលាយបាត់ពីផ្ទៃទន្លេនោះទៅៗ ។ ឱ! សំណាង អ្នកស្ទើរតែស្រឡប់បាត់ស្មារតី ក្នុងឱកាសដែលឃើញសុបិននិមិត្តទាំងប្លែកស្រស់បែបនេះ, ចិត្តអ្នកជាប់ជំពាក់លើមាតុគ្រាមយ៉ាងខ្លាំងមហិមា ស្ទើរតែទប់ចិត្តប្លែកពុំបាន ព្រោះជាហេតុនាំឲ្យឃើញយ៉ាងជាក់ស្តែងពេក, អ្នកខំពិចារណា ដើម្បីប្រៀបជាមួយនឹងសង្គ្រាមចុះកុំឲ្យចិត្តនេះស្ទុះស្ទាទៅរកអារម្មណ៍នោះខ្លាំងពេក ។

ខ្ញុំសូមជំរាបមិត្តអ្នកអានថា តើហេតុដូចម្តេចបានជាសំណាងឃើញរូបនារីធន-សារឿនលើផ្ទៃទន្លេនេះ?

ថ្ងៃនេះជាថ្ងៃឧបោសថ នារីធន សារឿនត្រូវឧបោសថ ហើយក៏នឹកភ្នកដល់បណ្តាំឪពុកនាង អំពីប្រអប់តូចមួយនៅក្នុងទូដែក ពេលនោះនាងបានបាក់ទូដែកហើយយកប្រអប់តូចនោះចេញមក ហើយចូលទៅក្នុងបន្ទប់សម្ងាត់របស់បិតានាង, នាងបានដុតធូបទៀននមស្សការព្រះរតនត្រ័យចំពោះធាតុបិតានាង ហើយក៏ពោលរំលឹកដល់បណ្តាំទាំងប៉ុន្មានរួចហើយ ក៏យកប្រអប់នោះមកបើកមើល, គ្រាន់តែនាងយកដៃដាក់លើគំរបប្រអប់នោះកាលណាគំរបនោះក៏របើកឡើងឯង នៅខាងក្នុងប្រអប់នេះគ្មានវត្ថុអ្វីប្លែកទេ មានតែថ្មកែវមួយផ្ទាំងតូចដែលក្រាលពេញបាតប្រអប់ សណ្ឋានជាកញ្ចក់ថ្លុះ នាងបានឈោងដៃទៅស្ទាបអង្អែលលើផ្ទាំងសិលាកែវតូចនោះ បន្តិចក្រោយមកក៏លេចមុខសំណាងកំពុងតែញញឹម ហើយធ្វើមាត់មុបៗ ដូចជាប្រាប់ហេតុអ្វីមួយដល់នាង, នាងត្រេកអរយ៉ាងក្រៃពេកក៏តបដោយស្មានទៅវិញថា ប្អូនស្មានតែបងស្លាប់បាត់បង់ទៅហើយ, សព្វថ្ងៃនេះប្អូននៅរង់ចាំតែបងប៉ុណ្ណោះទេ ដែលអាចគ្រប់គ្រងប្អូនទៅអនាគត ប្អូននឹងមិនទទួលយកអ្នកណាមួយដោយដាច់ខាតគ្រាន់តែចប់សំដីនោះភ្លាម រូបសំណាងរលាយបាត់ពីផ្ទៃសិលាកែវតូចនោះទៅ នាំឲ្យនាងយំសោកស្រណោះអាឡោះអាល័យយ៉ាងក្រៃលែង ។ បើសិនជាជនណាមួយបានមកជួបប្រទះនាងក្នុងពេលនេះប្រហែលជាគេស្មានថា នាងយំសោកព្រោះតែអាល័យបិតាកំសត់របស់នាងជាមិនខាន, តែការស្មាននោះខុសស្រឡះ នាងយំព្រោះសុបិនប្លែកស្រស់ទេ ដែលជាហេតុធ្វើចិត្តនាងឲ្យរន្ធត់យ៉ាងក្រៃលែង ។

(មានត)

★

★ ★

# ការធ្វើស្ករ

ដោយបណ្ណាធិការទស្សនាវដ្ដី មកនិយាយនឹងខ្ញុំឲ្យជួយនិពន្ធខាងផ្នែកវិទ្យាសាស្ត្រ, ខ្ញុំក៏មានយោបល់ស្របទៅតាមគោលបំណងរបស់ទស្សនាវដ្ដីនេះដែលចាត់ទុកជាពន្លឺរបស់ជាតិមួយក្នុងកម្ពុជរដ្ឋ ដំបូងនៃការនិពន្ធអត្ថបទវិទ្យាសាស្ត្រនេះ សូមអភ័យទោសពីករីទាំងឡាយដោយសុទ្ធចិត្ត ព្រោះថាជាលើកដំបូងបង្អស់នៃការទាក់ទងរវាង ទស្សនាវដ្ដីមិត្តសាលាបាលីនឹងខ្ញុំ

បញ្ញាចិត្ត

គ្មាននរណាអាចនិយាយថាមិនស្គាល់ស្ករសោះឡើយ លោកអ្នកធ្លាប់បរិភោគស្ករតាំងពីនៅក្មេងៗ សព្វថ្ងៃកុមារតូចៗ សូម្បីពុំទាន់ចេះនិយាយក៏ចេះដេញរកជាតិស្ករ លុះធំឡើងក៏បរិភោគស្ករទៀតស្ទើរតែរាល់ថ្ងៃ ៗ យើងដាក់ស្ករផ្សំនឹងកាហ្វេ-នំ-អាហារជាដើម ដូនភាលថ្នាំគ្រូពេទ្យខ្លះក៏មានជាតិស្ករលាយផងដែរ ៗ កាលសម័យសង្គ្រាមលោកលើកទីពីរ ស្ករបានធ្វើឲ្យមនុស្សខ្លះទៅជាសេដ្ឋីមកច្រើនគ្នាហើយៗ នៅពេលជាមួយគ្នានេះស្ករបានបណ្ដាលឲ្យប្រជាជនច្រើនប្រទេសក្នុងលោកខ្វះខាត ក៏សឹងមានដែរ ៗ នៅពេលដែលសេដ្ឋីខ្លះ, ក្នុងសម័យសង្គ្រាម, កំពុងប្រមូលទិញស្ករមកទុកលក់យកចំណេញផ្ទាល់ខ្លួន, ទាហាននៃប្រទេសជាច្រើនដែលត្រូវបញ្ជូនទៅច្បាំងនៅទីសមរភូមិ ដែលកំពុងអត់ឃ្លានរង់ចាំបរិភោគ ត្រូវជួបប្រទះនឹងបញ្ហាខ្វះជាតិស្ករ អង្គុយបរិភោគកាហ្វេល្ងាចរាល់ពេលបរិភោគអាហារ តើលោក-អ្នកអាចស្មានដល់ផលអាក្រក់ដែលបណ្ដាលមកពីការខ្វះជាតិស្ករក្នុងរាងកាយយើងនេះដែរឬទេ ?

បើប្រសិនជាសង្គ្រាមលោកលើកទី ៣ អាចកើតឡើងមែននៅអនាគតនេះ តើយើងអាចអត់ស្ករឬខ្វះស្ករបរិភោគទៀតឬទេ ? នៅសម័យបច្ចុប្បន្ននេះ ឧស្សាហកម្មផលិតស្ករសម្រាប់ប្រទេសខ្មែរយើង នៅក្នុងសភាពទុរទន់ទុកជាខ្វាំង ពុំទាន់បានឈ្មោះថាជាឧស្សាហកម្ម ដ៏ពិតប្រាកដសម្រាប់ប្រទេសបាននៅឡើយ ៗ យើងមានកន្លែងធ្វើស្ករតូចៗមួយកន្លែងប៉ុណ្ណោះនៅទីក្រុងភ្នំពេញ ហើយរោងធ្វើស្ករនេះ ក៏ពុំទាន់បានចាត់ធ្វើតាមគ្រោងការដ៏ត្រឹមត្រូវតាមគោលទ្រឹស្ដី (Theory) ប៉ុន្មានដែរ ៗ យើងយល់ថាកន្លែងធ្វើស្ករនេះមិនខុសអំពីមនុស្សឈឺ គឺដើរៗ ឈប់ៗ ដំណើរការនេះសោត ក៏ពុំទាន់មានរបៀបត្រឹមត្រូវនឹងស្ថិតិគួរឲ្យពេញចិត្តនៅឡើយ ព្រោះខ្វះអ្នកជំនាញការមកត្រួតត្រាឲ្យបានដិតដល់ ឯម្ចាស់រោងឧស្សាហកម្មចេះតែចង់បានផលច្រើនលើកំឡាំងអ្នកដៃទហួសប្រមាណដោយការរំលែកផលិតផលស្ដួចស្ដើងពេកទៅលើកម្មករ, ដូចនេះឃើញថាមិនមានការចំរើនទៅមុខប៉ុន្មាន ៗ ដើម្បីនឹងឲ្យលោក-អ្នកជ្រាបវិធីធ្វើស្ករយ៉ាង

ឆ្ងាយៗ ក្រែងថ្ងៃក្រោយលោក-អ្នកនឹងមានឱកាសអាចធ្វើស្ករទុកបរិភោគខ្លួនឯងក្នុងស្រុកយើងបាន ខ្ញុំបាទសូមជូនវិធីធ្វើស្ករយ៉ាងសង្ខេបដូចខាងក្រោមនេះ ។ គេច្រើនធ្វើស្ករពីទឹកអំពៅ ព្រោះអំពៅជាដំណាំឆាប់ធំ ហើយឆាប់បានផលផងមានទឹកផ្អែមច្រើន ដែលយើងអាចយកទៅធ្វើជាស្ករបានយ៉ាងល្អ ក្រៅអំពីនេះផ្លែឈើឯទៀតដែលមានជាតិផ្អែម ក៏អាចយកទៅធ្វើជាស្ករបានដែរ ដូចជា ដូង-ត្នោត ដែលយើងហៅថា ស្ករដូង ស្ករត្នោត ជាដើម ។ ផ្លែឈើខ្លះនៅប្រទេសអឺរ៉ុប និងប្រទេសអាមេរិក ក៏អាចធ្វើស្ករបានដែរ តែយើងសូមនិយាយចំពោះការធ្វើស្ករពីជាតិអំពៅសិន ព្រោះយើងអាចដាំអំពៅបានគ្រប់កន្លែង គ្រប់ខេត្តនៅប្រទេសខ្មែរ ព្រោះអាកាសធាតុមានអំណោយឲ្យយើងធ្វើបាន នៅខ្វះតែយើងពុំបាននាំគ្នាយកចិត្តទុកដាក់បង្កើតផលឲ្យបានពិតប្រាកដប៉ុណ្ណោះ យើងរវល់តែផ្តេកផ្តិតសង្ឃឹមចាំជនបរទេសមានអាមេរិកាំងជាដើម ដែលគេនឹងដឹកស្ករមកលក់ឲ្យយើងបរិភោគយ៉ាងថោកគួរសម ។ រឿងនេះយើងក៏អស់ភ្លេចគិតដល់អនាគតនៃប្រទេស ចុះបើមានកើតចម្បាំងឡើង តើយើងពឹងនរណាបានទៀតក្នុងស្ថានការណ៍ដ៏លំបាកនេះ ?

ដើមអំពៅ.— លោក-អ្នកធ្លាប់ស្គាល់ដើមអំពៅហើយ តែលោក-អ្នកជ្រាបទេ ថាដើមអំពៅនេះមានធាតុប្រកបដូចតទៅ ៖

១- ធាតុទឹកច្រើនជាងគេ ក្នុងដើមអំពៅ មានទឹកប្រមាណ ៨០ ភាគរយ

២- ជាតិស្ករ ក្នុងដើមអំពៅមានជាតិស្ករប្រមាណ ១៩ ភាគរយ

៣- ធាតុដទៃទៀត ដូចជា រ៉ែ-អំបិល ប្រមាណ ១ ភាគរយ ។ ដើមអំពៅមានច្រើនបែបច្រើនយ៉ាង យើងត្រូវរើសយកតែពូជណាដែលល្អ ដើមធំខ្ពស់មានទឹកច្រើន ត្រូវប្រយ័ត្នកុំឲ្យសត្វល្អិតមកខាំជញ្ជក់ជាតិស្ករអំពៅពីដើម ជាការនាំឲ្យខូចប្រយោជន៍ ត្រូវថែទាំស្រោចទឹកជាញយៗ ទើបដើមវាបានធាត់ធំមានជាតិស្ករច្រើន កាលបើអំពៅបានផលល្មមកាប់ហើយ យើងត្រូវយកដើមអំពៅនោះមកគាបយកទឹក ។

ការគាបទឹកអំពៅ

ប្រដាប់សម្រាប់គាបយកទឹកអំពៅនោះ អាចធ្វើអំពីឈើក៏បាន ដូចយើងធ្លាប់ឃើញអ្នកគាបអំពៅយកទឹកលក់នៅមុខរោងភាពយន្ត ឬតាមផ្លូវ បើសិនជាប្រើគ្រឿងចក្រសម្រាប់គាបអំពៅ (Cane crusher) ដែលមានកម្លាំងខ្លាំងអាចគាបបានទឹកម្តងៗជាច្រើនក៏បាន

កាលបើបានទឹកអំពៅហើយ យើងយកទៅធ្វើជាស្ករភ្លាមពុំទាន់បានទេ ព្រោះថាបើធ្វើយ៉ាងនោះទៅនឹងបានផលជាស្ករធុនអន់ថោកៗ ព្រោះនៅក្នុងទឹកអំពៅនោះនៅមានកាកដែលសេសសល់លាយនៅឡើយ ត្រូវយើងប្រើវិធីជំរះទឹកអំពៅឲ្យស្អាតដូចតទៅនេះ ៖

១.— វិធីដាំឲ្យពុះ បើយើងត្រួតមើល

ក្នុងទឹកអំពៅ យើងឃើញមានក្រូត (Acid) ខ្លះ លាយជាមួយផង យើងអាចពិនិត្យមើលក្រូតនេះដោយគ្រឿងវិទ្យាសាស្ត្រតាមគោលនៃវិជ្ជាពេទ្យ ដូច្នេះយើងត្រូវដាំទឹកអំពៅដែលគាបបានហើយនោះជាមួយនឹងធ្យូងឆ្អឹងសត្វ (Bone charcoal) ឬទឹកកំបោរសរ (Soda Lime) លុះដាំឲ្យពុះហើយគេនឹងឃើញវត្ថុមិនស្អាតទាំងឡាយអណ្តែតមកខាងលើ យើងត្រូវដួសវត្ថុមិនស្អាតទាំងនេះចេញ ហើយត្រងនឹងសំពត់ឲ្យស្អាតម្តងទៀត នោះនឹងបានទឹកអំពៅថ្លាបរិសុទ្ធគ្មានមន្ទិល ឬក្រូតលាយជាមួយឡើយ ។

២.— វិធីត្រង បើត្រងដោយសំពត់ក៏មិនទាន់ស្អាតល្អ ត្រូវត្រងដោយធ្យូងឆ្អឹងសត្វ (Bone charcoal) ទឹកអំពៅនឹងរឹតតែថ្លាល្អ គួរយកទៅធ្វើជាស្ករបាន ។

ការធ្វើស្ករ—

ការរំងាស់ទឹកអំពៅឲ្យរីងខះ ការនេះធ្វើបានច្រើនយ៉ាង ដោយប្រើគ្រឿងចក្រគួរ (Centrifugal) បង្កើតបានជាគ្រាប់ស្ករតូចៗចេញមក ឬរំងាស់ដោយប្រើប្រដាប់ដែលប្រាសចាកធាតុអាកាស (Vaccuum Pan) ក៏បានផលដូចគ្នា ។

តាមសេចក្តីដូចបានអធិប្បាយខាងលើនេះគ្រាន់តែជាគោលៗដំបូងលោក-អ្នកឲ្យបានជ្រាបខ្លះថា ជាតិស្ករនេះធ្វើអំពីអ្វីខ្លះ ធ្វើយ៉ាងណា បើលោក-អ្នកចង់ផ្តើមគំនិតធ្វើមែនៗ ត្រូវសិក្សាស្រាវជ្រាវពីក្បួនតម្រាឲ្យបានជ្រៅជ្រះជាងនេះទៀត រឿងនេះប្រសិនជារាជ-រដ្ឋាភិបាលចង់ទំនុកបំរុងឧស្សាហកម្មប្រភេទនេះក្នុងប្រទេសយើង គប្បីបាត់បញ្ជូននិស្សិតខ្មែរឲ្យទៅសិក្សានៅប្រទេសដែលចំរើនខាងឧស្សាហកម្មធ្វើស្ករ ដើម្បីនឹងបានត្រឡប់មកបង្កើតឧស្សាហកម្មធ្វើស្ករក្នុងប្រទេសយើងឲ្យបានលូតលាស់ទាន់សម័យនឹងគេ បើធ្វើការនេះបានសម្រេចដូចខាងលើមែននោះ ខ្ញុំបាទជឿជាក់ថា ទោះបីមានសង្គ្រាមកើតឡើងក៏ដោយ ឬគ្មានក៏ដោយ ជនជាតិខ្មែរយើងគង់នឹងមានស្ករបរិភោគគ្រប់គ្រាន់ ដោយថ្លៃថោកជាងបច្ចុប្បន្ននេះជាច្រើន ។ នេះជាយោបល់មួយដែលខ្ញុំជូនចំពោះលោក-អ្នកទុកជាការពិចារណា ព្រោះយើងមិនមានបំណងនឹងដកដង្ហើមដោយច្រមុះនៃជនដទៃ ។

បញ្ញាចិត្ត

x x x

## បញ្ចតន្ត្រ (ត)

បើនឹងមានកិច្ចការអ្វីមួយមិនជាទីពេញចិត្តលោកម្ចាស់នុះ យើងត្រូវតែលោតចូលក្នុងគំនរភ្លើងសម្លាប់ខ្លួនទៅតាមក្រោយលោកម្ចាស់ទាំងអស់គ្នាមិនខាន, ព្រោះថា៖

៤៩១- បុរសណា ជាប្រធានក្នុងត្រកូល បុរសនោះត្រូវជនទាំងឡាយប្រឹងប្រែងថែរក្សាឲ្យពេញទំហឹង ព្រោះថាបើបុរសនោះវិនាសហើយ ត្រកូលខ្លួនទាំងមូលក៏ត្រូវវិនាសដែរ ដូចជាដុំកង់បាក់បែកហើយ គង់បរទៅមិនបានដោយពិត ។

លុះបានស្តាប់ពាក្យពីពោះនេះហើយ សីហៈនៅស្ងៀមមួយស្របក់ ទើបពោលថាៈ "បើដូច្នេះ ចូរឯងធ្វើតាមពេញចិត្តចុះ" ។ កាលនោះបបកបានទទួលពាក្យបង្គាប់ហើយ ចេញទៅក្រៅ ប្រាប់សត្វទាំងឡាយជាសម្លាញ់ថាៈ "នៃវើយ ! ម្ចាស់យើងអស់ទីពឹងហើយ ជម្ងឺលោកធ្ងន់ណាស់ហើយ នៅដង្ហើមតិចៗត្រឹមតែចុងច្រមុះទេ, អំណើះតអំពីលោកទៅ តើនរណាត្រូវគ្រប់គ្រងព្រៃនេះ? មកយើងបបួលគ្នាទៅ! ទៅគោរពម្ចាស់យើង ដែលលោករៀបធ្វើដំណើរទៅកាន់បរលោកខាងមុខហើយ ដោយជម្ងឺនឹងសេចក្តីស្រេកឃ្លាន ចូរយើងលះបង់ខ្លួនយើងជាទានបូជាលោកម្ចាស់យើង ដើម្បីតបស្នងសងគុណកតញ្ញូតាធម៌ចំពោះលោក, ព្រោះថា៖

២៩២- សេវកាមាត្យណាក៏ដោយមានជីវិតរស់នៅ ហើយម្ចាស់ខ្លួនបានទទួលសេចក្តីអន្តរាយ សេវកាមាត្យនោះ កាលបើខ្លួនមានជីវិតរស់នៅយ៉ាងនេះ (មិនជួយទុក្ខធុរៈទេ) នឹងទៅកាន់នរក ។

សត្វទាំងឡាយបានស្តាប់ពាក្យនៃបបកយ៉ាងនេះហើយ មានមុខទទឹកជោកដោយទឹកភ្នែកហូរហៀរស្រក់ បបួលគ្នាទៅក្រាបប្រណិប័តន៍ទៀបបាទជើងសីហៈហើយបិតនៅក្នុងទីសមគួរតែរៀងកាលខ្លួន ។ កាលឃើញសត្វទាំងឡាយត្រឡប់មកដល់អង្គុយជួបជុំគ្នាហើយ សីហៈសួរទៅកាន់សត្វទាំងឡាយនេះថាៈ "នៃអ្នកទាំងឡាយ ! ឯងទាំងអស់គ្នា ចាប់បានឬក៏បានឃើញសត្វអ្វីខ្លះដែរ?" ។ បណ្តាសត្វទាំងឡាយនោះ ក្អែកឆ្លើយថា "លោកម្ចាស់! យើងខ្ញុំទាំងអស់គ្នា បបួលគ្នាត្រាច់រង្គាត់គ្រប់ទីតំបន់ ទៅខាងនេះខាងនោះសព្វអស់ហើយ ប៉ុន្តែចាប់មិនបានសត្វអ្វីមួយសោះ សូម្បីគ្រាន់តែឃើញក៏មិនបានឃើញផង បើដូច្នេះ សូមលោកម្ចាស់ស៊ីខ្លួនខ្ញុំបាទជាអាហារសម្រាប់ថ្ងៃនេះចុះ ដើម្បីឲ្យលោកម្ចាស់មានជីវិតរស់នៅ តទៅមានតែផ្លូវ១ឆ្ងាយមួយនេះទេ ទើបលោកម្ចាស់នឹងប្រព្រឹត្តទៅបាន ចំណែកខ្ញុំម្ចាស់អាស្រ័យដោយកុសលនេះនឹងបានទៅកើតក្នុងឋានសួគ៌ផង ព្រោះថា៖

២៩៣- ខ្ញុំបំរើណាដែលមានភក្តីបានលះបង់ប្រាណដើម្បីបូជាម្ចាស់ ខ្ញុំបំរើនោះនឹងបានដល់សិវឋាន ដែលជាបរមសុខក្រៃលែង ឥតមានជរាមរណៈឡើយ ។

លំដាប់នោះ បបកបានស្តាប់ហើយនិយាយឡើងថាៈ "នៃបងក្អែក! បងឯងតូចណាស់ បើទុកជាលោកម្ចាស់ស៊ីរូបបង លោកម្ចាស់ក៏មិនមានជីវិតរស់នៅបានយូរប៉ុន្មានដែរ ហើយនឹងមានទោសដទៃទៀតកើតឡើងផង, ព្រោះថា៖

២៩៤- សាច់ក្អែកតិចផង មិនសូវមានរសជាតិផង គុំបាឡើយដល់ទៅសត្វណា សូម្បីតែក្អែកក៏មិនស៊ីសាច់ក្អែកផង មានប្រយោជន៍អ្វី បើស៊ីសាច់ក្អែកទៅហើយ មិនបានទាំងឆ្អែតស្កប់ស្កល់ដូច្នេះ? ។

តែបើទុកជាដូចម្តេចក៏ដោយ រូបបងបានសំដែងភក្តីចំពោះលោកម្ចាស់ហើយ ឈ្មោះថាបានតបស្នង

សនបំណុលគឺចំណីអាហារដែលលោកម្ចាស់បានឲ្យបងឯង, មួយទៀតដោយអំពើដ៏ប្រសើរនេះ បងបានកេរ្តិ៍ឈ្មោះប្រសើរនៅនាលោកនេះផង នៅនាបរលោកនាយផង ចូរបងចៀសចេញពីខាងមុខបន្តិច ទុកឲ្យខ្ញុំចូលទៅគោរពបូជាខ្លួនជូនលោកម្ចាស់ម្តង ។ ចចកនិយាយហើយចូលទៅក្រាបប្រណិប័តន៍សីហៈដោយគោរពដ៏ក្រៃលែង រួចហើយទើបពោលពាក្យថា: លោកម្ចាស់! សូមលោកម្ចាស់ធ្វើប្រាណ[១]យាត្រា គឺតម្រង់ជីវិតឲ្យបាននៅចិតថេរតទៅ ដោយយកខ្លួនខ្ញុំបាទនេះជាអាហារចំអែតផ្ទៃនេះ សូមលោកម្ចាស់ទទួលដោយត្រេកអរ ដើម្បីឲ្យខ្លួនខ្ញុំបាទបានប្រយោជន៍ក្នុងលោកនេះផង ទៅបរលោកនាយផង, ព្រោះថា៖

២៩៥- ប្រាណគឺជីវិតនៃខ្ញុំបំរើជាអាយ័តនៃម្ចាស់ ព្រោះជីវិតនៃខ្ញុំបំរើគឺម្ចាស់បានឲ្យ:ហើយដោយទ្រព្យ ការទទួលព្រមចាប់សម្លាប់នេះមិនមែនជាប្រភពនាំឲ្យកើតជាទោសទេ ។

តមកទៀត, ខ្លាកាលបានស្តាប់ពាក្យចចកហើយឆ្លើយតទៅថា៖

"នែបងចចក! បងឯងនិយាយនេះពេញជាត្រូវហើយ តែបងក៏មិនមែនមានខ្លួនធំណាស់ណាទេ ខ្លួនបងតូចណាស់ មួយទៀតបងជាតិជាមួយគ្នានឹងខ្ញុំ ព្រោះមានក្រញាំក្រចកដូចគ្នា បងមិនត្រូវប្រគល់ខ្លួនជូនលោកបរិភោគទេ, ព្រោះថា៖ (មានត)

១- ប្រាណយាត្រា ការប្រព្រឹត្តទៅនៃជីវិត (Subsistance) ។

# រឿងទុក្ករធ្វើជជាតិ (ត)

## ស្វាលួងលោមព្រះរាជិនី

ស្វាចង់លួងលោមព្រះរាជិនី, វាលោតនៅលើដង្គង់ព្រះនាង ហើយជូតទឹកនេត្រក្រាបបង្គំទូលថា:

"មាតា, ឱមាតា! ទ្រង់កុំសោកាអ្វី, ខ្ញុំនឹងបំបាត់នូវសេចក្តីទុក្ខរបស់មាតាឲ្យបាន? ខ្ញុំនឹងទៅឯដំណាក់ប្រាំពីរជាន់ នឹងឧទ្យានទាំងប្រាំពីរ ព្រមទាំងទាសីប្រាំពីររយនាក់ ព្រះមាតានឹងត្រឡប់ទៅកាន់ឋានន្តរៈជាព្រះរាជិនីដូចដើមប្រកបដោយសេចក្តីសុខសប្បាយ? គង់ជិតព្រះមហាក្សត្រិយ៍ នៅក្នុងព្រះដំណាក់មាស ហើយខ្ញុំនឹងយកព្រះរាជបុត្រមួយអង្គមកឲ្យគង់លើដង្គង់ព្រះមាតា មានរស្មីកាំភ្លឺចែងចាំងក្រហមព្រាលភ្លៅដូចព្រះចន្ទមាស ។ បើបានបំពេញករណីយកិច្ចបែបនេះចំពោះព្រះមាតា ទើបខ្ញុំមាននាមឈ្មោះថាស្វាកូត ។ សូមព្រះមាតាប្រតិបត្តិតាមពាក្យឱវាទរបស់ខ្ញុំ ហើយមិនយូរមិនឆាប់មុខជាព្រះមាតាបានសុខព្រះកាយ សប្បាយព្រះទ័យក្នុងព្រះដំណាក់មាស ប្រកបដោយសេចក្តីស្នេហា មានទាសីអាមាត្យហោមរោមជាកិត្តិយស ព្រមទាំងសម្បូណ៌ដោយភោគទ្រព្យដូចពីអតីតកាល? ។

ព្រះនាងទុក្ខពទីទ្រង់ព្រះសណ្តាប់នូវសត្វព៌ចាស្វាក៏មានទឹកព្រះនេត្រស្រោចស្រប់ជោកព្រះភក្ត្រា តែទ្រង់មានរីមព្រះឱស្ឋញញឹមស្ងួត; ព្រះនាងទ្រង់សើចផង សោយសោកាផង, មានបន្ទូលថា "ឱ! ស្វាជា

ទីស្រឡាញ់ពេញចិត្តរបស់មាតា, បើមាតាដឹងថាតើមានសត្វចំនួនប៉ុន្មាន ដែលមាតាបានធ្វើពលីកម្មទៅព្រះវិហារគ្រប់កន្លែង តើមានផ្កាយប៉ុន្មាន ដែលមាតាយកទៅថ្វាយគ្រប់បូជនីយដ្ឋាន ! បើទុកជាយ៉ាងណាក៏ដោយ, នៅតែព្រះមាតាគ្មានព្រះរាជបុត្រ ។ ឱ ! ស្វាក្រៃអើយ នាងឯងនឹងប្រព្រឹត្តយ៉ាងណាខ្លះ ? បន់ស្រន់អ្នកណា ? ឬមានកិច្ចសន្យានឹងទេវបុត្រទេវតាដែលណា ? បានជានាងអាចនាំព្រះរាជបុត្រឲ្យមកគង់លើជង្គង់មាតា ដែលមាតាប្រាថ្នាយ៉ាងមុតមាំ ។ ចូរនាងទុកព្រឹត្តិការណ៍ឲ្យទៅតាមកាលៈទេសៈចុះ, ឱ ! ស្វាក្រៃជាទីស្រឡាញ់របស់មាតា ទុកឲ្យព្រះមហាក្សត្រគង់នៅជាសុខជាមួយនឹងបច្ចាមិត្តរបស់មាតាហើយ ឲ្យសេចក្តីទុក្ខរបស់មាតាស្ងាត់នៅដូចដើមចុះ ។ នាងឯងចង់ធ្វើការដែលហួសមាឌ, ផុតនិស្ស័យ ! ជិតយប់ដល់ហើយ, ស្វា, នាងឯងមកសម្រាកជិតមាតា ។

ស្វាក្រាបទូលថា ៖

— "ទេព្រះមាតា, ខ្ញុំដេកមិនលក់ទេ" បើមាតាមិនទុកចិត្ត ។

— ព្រះនាងមានបន្ទូលតបថា: "ចូរនាងដេកទៅ, ចូរនាងដេក; យប់យូរហើយ" នោះព្យុះខ្លាំងកើតឡើងពីទិសខាងលិច ទៅខាងកើត ។ ពពកសណ្តោតលឿនរហ័ស, ភ្លៀងធ្លាក់ដូចជាគេបែកមេឃ ហើយសត្វនិករពាំងឡាយ ផ្ទុយផ្អើកផក់គ្រប់ៗគ្នា ពាំងប្រទេសពាំងមូល ។ មាតាក្រាលកន្ទេះនៅលើដី, ខ្យល់បក់ត្រជាក់, ត្រូវតែដេក ! មកនេះលើជង្គង់មាតា, ចូរនាងដេកសម្ងំក្នុងហទយវត្ថុមាតា ។

ស្វាដេកយកក្បាលផ្អាល់នៅនឹងឧរៈព្រះនាង, ព្រះរាជិនីទ្រង់កើយព្រះសិរលើសំពត់កន្ទេះ ហើយផ្ទំលក់មួយរំពេច... ។

ព្រះរាជិនីផ្ទំនៅលើកន្ទេះរហែកដាច, នៅក្នុងខ្ទមចាស់ទ្រុឌទ្រោម, ទឹកភ្លៀងធ្លាក់ស្រោចពាសពេញគេហដ្ឋាន ដោយដំបូលរបើកចេញព្រោះព្យុះសង្ឃរា, ចំណែកឯព្រះរាជិនីក្មេងផ្ទំនៅលើព្រះទែនមាស, លើពូកដែលមានបុប្ផារាយពាសពេញក្រអូបឈ្ងុយឈ្ងប់, ជាសុខសប្បាយនៅជិតព្រះមហាក្សត្រ ។

x x

x

ស្វាចេញបាត់

បុព្វណ្ហសម័យមកដល់ហើយ,

ខាងព្រះបរមរាជវាំង, គងធំដែលគេវាយតាមម៉ោងឮលាន់ខ្ទរខ្ទារក្នុងបមយាម, គេបានឮសូរស័ព្ទខ្លុយផ្សាយចេញពីណាបាតខាន: (Nabat Khana).(១)

(មានត)

(១) ណាបាតខាន: ឬផ្ទះភ្លេងគឺជាបន្ទប់មានបន្ទប់ជាច្រើនស្ថិតនៅជិតក្លោងទ្វារក្នុងព្រះបរមរាជវាំងហើយមានពួកអ្នកលេងភ្លេងរាគីនីស (Raguinis) បទផ្សេងៗទៅតាមម៉ោងក្នុងមួយថ្ងៃៗ ។

# ១- ជីវិតអភ័ព្វ

បុណ្ណកុមារ
ដោយ សួន-សុរិន្ទ

សម័យមួយ ទេវតីនគរជានគរដែលរុងរឿង ឧត្តមសម្បូណ៌ដោយធញ្ញាហារ ជានគរដែលល្បីឈ្មោះជាងនគរទាំងឡាយនៅបរិវេណដើមទន្លេគោធាវរី ជានគរដែលប្រដាប់ដោយទង់ជាយនិងទង់ជ្រុង បើក្រឡេកមើលពីចម្ងាយក៏គួរនឹងចាប់ភ្នែក មានសម្លេងដូរ្យតន្ត្រីប៉ីប្រគំ ស្គរ ស័ង្ខលាន់ឮឡើងមិនដាច់ស្នូរ ៗ អ្នកនគរទាំងឡាយប្រដាប់តាក់តែងកាយដោយគ្រឿងអលង្ការផ្សេងៗសុទ្ធសឹងតែមានតម្លៃនាំគ្នាដើរខ្វាត់ខ្វែងសើចលេងសប្បាយពាសពេញវិថីនានាក្នុងក្រុងដោយទឹកមុខដ៏ញញឹមញញែមស្រស់បស់ តែកន្លែងដែលមានមនុស្សណែនណាន់តាន់តាប់ច្រើនជាងគេគឺនៅសួនច្បារខាងមុខព្រះបរមរាជវាំង ព្រោះទីនោះ វេលាដែលព្រះអាទិត្យរៀបនឹងអស្តង្គតទៅ ព្រះបាទទេវរាជជាព្រះរាជាអគ្គបិតានៃទេវតីនគរទ្រង់នឹងធ្វើពិធីព្រះរាជាភិសេកចំពោះមុខសមណព្រាហ្មណ៍ និងប្រជារាស្ត្រទាំងឡាយ ដែលជាព្រះរាជពិធីដ៏ធំសំខាន់ ដែលនឹងមានឡើងម្តងៗ ក៏ទាល់តែមានការផ្លាស់ប្តូរផែនដីប៉ុណ្ណោះ ដូច្នោះទេវតី ទើបមានសភាពហ៊ឹកហ៊ាក់សប្បាយ មានមនុស្សហូរមកពីទិសានុទិស ដើម្បីនឹងមកចាំមើលព្រះបារមីនៃព្រះរាជាអគ្គបិតាដោយត្រៀបត្រា ៗ

នៅលើសាលាធាតុតូចមួយដែលតាំងនៅជិតវត្តខាងជាយក្រុង ខណៈនោះមានបុរសចាស់ជរាប្លោកស្គមម្នាក់ ដេកសន្ធឹងសន្ធៃដោយសេចក្តីនឿយព្រួយនឹងអស់កម្លាំង ៗ សម្លេងហ៊ឹកហាក់នៃមនុស្សនិងសម្លេងគងរគាំងដែលលាន់ឮមកពីចម្ងាយក៏មិនធ្វើឲ្យគាត់នឹកនាយកចិត្តទុកដាក់អ្វីសោះឡើយ គាត់បែរជាដកដង្ហើមធំៗ វែងៗ ធ្មេចភ្នែកទៅដោយសេចក្តីហត់នឿយព្រមទាំងថ្ងូរហ៊ុំៗ ៗ

នៅពេលដែលកំពុងតែថ្ងូរនោះ ក៏ស្រាប់តែមានក្មេងតូចម្នាក់អាយុប្រហែលជា ៨ ឆ្នាំ ឡើងដើរមកជិតតាចាស់នោះហើយសួរដោយសម្លេងស្រាលៗថា

"តា! តា! តាបាត់ឈឺហើយទៅ? តេវាយតង់ធ្វើអ្វីហ្នឹងតា?"

តាចាស់ជរានៅស្ងៀមមិនឆ្លើយថាអ្វី ព្រោះគាត់កំពុងតែឈឺយ៉ាងធ្ងន់ គ្មានកម្លាំងល្មមនឹងឆ្លើយបាន តែគាត់បើកភ្នែកឡើង ហើយសម្លឹងមើលមុខចៅដែលនៅមិនទាន់ដឹងក្តីកំពុងតែត្រសុលមកជិតហើយឱនមុខមកជិតគាត់

"តាម្តេចក៏មិននិយាយនឹងខ្ញុំ? បានអីញ៉ាំ? ខ្ញុំឃ្លានណាស់" ក្មេងនោះនិយាយតទៅទៀត ព្រមទាំងលូកកាវែកមើលអ្វីក្នុងថង់យាមដែលតាចាស់ជរានោះដាក់ទុកជិតខ្លួន ហើយទាញយកបានអ្វីមួយចេញមកក្រៅ ហើយលូកកាវែកទៀត តែមិនមានអ្វីដែលនឹង

រម្ងាប់នូវការស្រេកឃ្លានបានឡើយ ។

"ខ្ញុំឃ្លានណាស់តា!" ក្មេងនោះនិយាយព្រមទាំងទាញចំណងកបុះឡើង ដែលមានគ្រាប់ផ្គាំផ្ញើដោយក្អុកដំរីបង្អាប់ជាមួយផងនោះ ៤ គ្រាប់ ។ កាលបើគ្រាប់ផ្គាំនោះទង្គិចគ្នាក៏ឮឡើង "ក្រិក! ក្រិក!" ឯក្មេងនោះក៏រឹតតែទាញបុះឡើងៗឲ្យទង្គិចគ្នាទៀត ហើយមើលទៅរូបជារីករាយនឹងសម្លេងនោះទាល់តែភ្លេចទឹក-នាទៅមួយសន្ទុះថាខ្លួនកំពុងតែឃ្លាន ។

បុរសចាស់ជរានោះ ខំបើកភ្នែកក្រឡេកមើលទៅហើយដកដង្ហើមធំ រួចក៏ឈ្ងោចទៅវិញ ។

សម្លេងហោកញ្ជ្រៀវបានលាន់ឮមកពីចម្ងាយបីដង ។ ពិធីព្រះរាជាភិសេកកំពុងតែនឹងបញ្ចប់ចុះហើយ ។ សម្លេងត្រែ ស័ង្ខ រគាំង ឃ្មោះទឹងមហោរីបានបន្លឺឡើងមកពីចម្ងាយ ។ កុមារតូចលែងលេងគ្រាប់ផ្លាំ បែរជាផ្ទៀងត្រចៀកស្តាប់សម្លេងនោះ ។ អ្នកឈឺភ្នែកហើយស្វាប ក្នុងទីបំផុតក៏ប្រាសខ្លួនដេកក្បែរតាចាស់ជរានោះ ដៃទាំងពីរកាន់ផ្គាំជាប់ ភ្នែកទាំងពីរបិទជិតឲ្យសញ្ញាថា ដេកលក់ហើយទាំងដែលខ្លួនមានការស្រេកឃ្លានយ៉ាងខ្លាំង ដោយគ្មានអាហារដាក់ពោះមួយគ្រាប់សោះឡើយតាំងពីព្រឹកមកម្ល៉េះ ។

គ្មានអ្នកណាមួយបានដឹងសោះឡើយថា តាចាស់ជរានឹងកុមារនោះជាអ្នកណា? មកពីណា? ព្រះសង្ឃក្នុងវត្តនោះក៏គ្រាន់តែដឹងថា ជាតានឹងចៅប៉ុណ្ណោះហើយអ្នកទាំងពីរបានមកសូមសំណាក់អាស្រ័យនៅនឹងសាលានេះអស់វេលា ១០ ថ្ងៃមកហើយ ។ មានរបរចិញ្ចឹមជីវិតដោយការសូមទាន ។ តាចាស់ជរានោះក៏បេះតែឈើទ្រុឌទ្រោមគ្រាំគ្រែងជានិច្ច ក្នុងទីបំផុតក៏ឈឺខ្លាំងឡើងទាល់តែក្រោកមិនរួច ។ ព្រះសង្ឃលោកអាណិត ក៏បានយកបាយសម្លនឹងថ្នាំសង្កូវមកឲ្យតែជម្ងឺរបស់តាចាស់ជរានោះ ក៏បេះតែទ្រុឌទ្រោមខ្លាំងឡើងៗ ។

ថ្ងៃល្ងាចហើយ ពន្លឺដ៏ស្រទន់នៃព្រះអាទិត្យស្ទើរតែនឹងអស់ទៅហើយ ព្រះរាជពិធីរាជាភិសេកក៏បានរួចរាល់អស់ហើយ ។ ពួកមនុស្សដែលបានទៅក្នុងពិធីបុណ្យនោះ ក៏បានត្រឡប់ទៅគេហដ្ឋានវិញរៀងៗខ្លួន ។ វត្តជាយក្រុងជាវត្តដែលតាំងនៅឆ្ងាយពីទីប្រជុំជន យូរៗទើបមានមនុស្សដើរកាត់មកត្រង់វត្តនោះម្តងៗ ។

ខណៈនោះមានមនុស្សមួយពួកដើរកាត់មកក្បែរសាលាឆទានជិតវត្តដែលជាទីសំណាក់អាស្រ័យនៃតា-ចាស់ជរានឹងចៅនោះ ។ បណ្តាអ្នកទាំងនោះ មានម្នាក់ស្លៀកខោព័ណ៌ក្រហមពាក់អាវព័ណ៌លឿង ពាក់មួកស៊ីបទ្រុបដែលមានដោតស្លាបក្ងោកជាលំអរពីលើជាគ្រឿងសំគាល់ថា អ្នកស្លៀកពាក់បែបនេះជាអ្នកមានតំណែងខ្ពស់ក្នុងព្រះរាជវាំង ។ បុរសនោះមានវ័យកណ្តាល មុខពារអង់អាច ស្ពាយដាវស្រោមមាសព័ទ្ធចៀង ។

(មានត)



នេះជាចេតិយអនុស្សាវរីយព្រះសារីរិកធាតុ ដែលពុទ្ធបរិស័ទប្រទេសកម្ពុជា បានផ្ដើមសាងឡើង នៅទីចំពោះមុខស្ថានីយរេយស្ដ័យយាន ប្រទេសកម្ពុជា ដើម្បីជាការលើកដល់ដំណើរដ៏អស្ចារ្យនៃព្រះបរមសារីរិកធាតុមួយអង្គដោយ អគ្គសាវកធាតុ បានយាងមកកាន់ប្រទេសកម្ពុជា ជាលើកដំបូង ហើយជាកន្លែងដែលប្រតិភូនានា ខាងព្រះពុទ្ធសាសនាបានប្រជុំគ្នាធ្វើសេចក្ដីគន់ទីនេះ ។



នេះជាព្រះវិហារផ្គូលត្ថា, ដែលបាក់បែក គ្រាំគ្រាយូរយារណាស់មកហើយ, រូបភាពដែល បង្ហាញឲ្យឃើញនេះ ចំពោះការកែលំអផ្គូរសាង ឡើងវិញ ។ ការកសាងដែលគេចាប់សាង ឡើងសព្វថ្ងៃនេះមាន៣ជាន់តែ ចំពោះជាន់ ១ ក៏បានសាងឡើងហើយ នៅសល់ជាន់ទីពីរទៀត ពុទ្ធបរិស័ទទាំងឡាយ កំពុងតែជាប់ដំណាក់លើការ កសាងនេះគ្រប់ៗគ្នា ។ យើងខ្ញុំមានសេចក្ដីសង្ឃឹមលើពុទ្ធបរិស័ទទៅជាទីជួយបង្ហើយចំពោះមហាកុសលនេះផង ។

## ជូនដំណឹង

ដល់ពេលកំណត់ហើយ ខ្ញុំនឹងបោះពុម្ពសៀវភៅ "គ្រាប់បុប្ផាសារពត្ត" នៅត្រឹមថ្លៃ ២០ រៀល មួយក្បាល · សូមមិត្តអ្នកអានគ្រប់បណ្ណាគារទូទៅ ។ ឬក៏ផ្ញើប្រាក់មកបណ្ណាធិការ វត្តឧណ្ណាលោម នៅ ស្រុកក្រៅផ្ញើទៅជាប្រាក់ធនាគារ សម្រាប់ប្រគេនព្រះសង្ឃក្នុងពេលកំណត់នោះ ។

បណ្ណាធិការ

រោងពុម្ពអ៊ឹក-ប៊ុ-គុណ វិថីប៉ាស្ទ័រ ភ.ព.